ធនាគារ ភ្នំពេញ ពាណិជ្ជ

Phnom Penh Commercial Bank

# របាយការណ៍ប្រចាំឆ្នាំ ២០១០

# ANNUAL REPORT 2010




ការិយាល័យកណ្ដាល: លេខ ៧៦៧-៧៦៩ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩៩៩ ៥០០ ទូរសារលេខ: (៨៥៥) ២៣ ៩៩៩ ៥៤០ អ៊ីម៉ែល: service@ppcb.com.kh គេហទំព័រ: www.ppcb.com.kh
**SWIFT:** PPCBKHPP




សាខាបីអេស: អគារបីអេស មហាវិថីព្រះមុនីវង្ស សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩៩៩ ៦០០ ទូរសារលេខ: (៨៥៥) ២៣ ៩៩៩ ៤០០




សាខាផ្សារដើមគ: លេខ ៧៨ មហាវិថីព្រះមុនីរ៉េត សង្កាត់ទួលស្វាយព្រៃ២ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩៩៩ ៧០០ ទូរសារលេខ: (៨៥៥) ២៣ ៩៩៩ ៧០១

# ចក្ខុវិស័យ គោលដៅស្នូល និងបេសកកម្ម

## ធនាគារដែលបង្កើតនូវអនាគតដ៏ត្រចះត្រចង់របស់ប្រទេសកម្ពុជា

### ចក្ខុវិស័យ

ធនាគារដែលបង្កើតនូវ អនាគតដ៏ត្រចះត្រចង់របស់ប្រទេសកម្ពុជា តាមរយៈហិរញ្ញវត្ថុឈានមុខគេ និង ទំនុកចិត្ត ។

### គោលដៅស្នូល

ជាធនាគារមួយក្នុងចំណោមធនាគារល្អបំផុតចំនួន ៥ ក្នុងប្រទេសកម្ពុជា ។

### បេសកកម្ម

១. បំពេញតំរូវការរបស់អតិថិជន
២. កែលំអតំលៃនៃនិមិត្តសញ្ញា
៣. បង្កើនជាអតិបរិមានូវប្រសិទ្ធភាព

### ទស្សនៈវិស័យ

**ធនាគារ ភ្នំពេញពាណិជ្ជ កំពុងបង្កើតតំលៃថ្មី**

បណ្តាប្រទេសអាស៊ីអាគ្នេយ៍ បានបង្ហាញពីការអភិវឌ្ឍន៍សេដ្ឋកិច្ច និងនយោបាយដ៏អស្ចារ្យនាឆ្នាំថ្មីៗនេះ ដែលបានប្រែក្លាយរូបភាពរបស់ខ្លួនប្លែកពីគេ និងកាន់តែរីកចំរើន ។ ហេតុដូច្នេះហើយ ទីផ្សារហិរញ្ញវត្ថុអន្តរជាតិរំពឹងទុកថាបណ្តាប្រទេសទាំងនេះនឹងក្លាយជាប្រភពហិរញ្ញវត្ថុរួមថ្មីមួយ ។ ប្រទេសកម្ពុជាជាបេះដូងនៃទីផ្សារកំពុងអភិវឌ្ឍន៍ដ៏សំបើមនេះ ។ ឥឡូវនេះ ធនាគារ ភ្នំពេញពាណិជ្ជ ដែលបានចូលរួមជាមួយទីផ្សារហិរញ្ញវត្ថុដ៏រីកចំរើនរបស់ប្រទេសកម្ពុជាប្តេជ្ញាអោយក្លាយជាអ្នកបង្កើតតំលៃ ដែលមានតែមួយ ដោយកែលំអតំលៃរួម របស់ប្រទេសកម្ពុជា ។

# ការគូសបញ្ជាក់អំពីហិរញ្ញវត្ថុ

| | ២០១០ | ២០០៩ | ២០០៨ |
|---|---|---|---|
| **លទ្ធផលប្រតិបត្តិការ (គិតជាពាន់ដុល្លារអាមេរិក)** | | | |
| ចំណេញមុនពេលបង់ពន្ធ | ៧២៨ | ៣៨១ | (៥១៥) |
| ចំណេញសុទ្ធក្រោយពេលបង់ពន្ធ | ៥៩៤ | ៣៥៩ | (៥១៧) |
| **ទិន្នន័យគន្លឹះតារាងតុល្យការ (គិតជាពាន់ដុល្លារអាមេរិក)** | | | |
| ទ្រព្យសកម្ម | ៥៨.៣៥១ | ៣៤.០៤៥ | ១៩.២១០ |
| ឥណទាន និងបុរេប្រទាន | ២៤.៤៩៩ | ១២.៦៦០ | ៥.២៨៨ |
| ប្រាក់បញ្ញើពីអតិថិជន | ៤២.១០៨ | ១៩.១២៣ | ៤.៦៩៦ |
| ដើមទុន | ១៥.០០០ | ១៥.០០០ | ១៥.០០០ |
| មូលនិធិម្ចាស់ហ៊ុន | ១៥.៤៣៧ | ១៤.៨៤២ | ១៤.៤៨៣ |
| **អនុបាតហិរញ្ញវត្ថុ (គិតជាភាគរយ)** | | | |
| ការបង្វិលចំណូលលើទ្រព្យសកម្ម | ១,០២ | ១,០៦ | (២,៦៩) |
| ការបង្វិលចំណូលលើមូលនិធិម្ចាស់ហ៊ុន | ៣,៨៥ | ២,៤២ | (៣,៥៧) |
| អនុបាតសាច់ប្រាក់ងាយស្រួល | ១៤០,៣៣ | ១៨៥,១០ | ៤៤២,៨២ |
| អនុបាតសាធនភាព | ៣០,០៤ | ៤៨,៣៧ | ៩៦,៨១ |

# តារាងតុល្យការបំព្រួញ

## ទ្រព្យសកម្ម

### ២០០៩




### ២០១០




## ទ្រព្យអកម្ម និងមូលនិធិម្ចាស់ហ៊ុន

### ២០០៩




### ២០១០



# ការសង្ខេបទៅលើកំណើន ៣ឆ្នាំ













ធនាគារ ភ្នំពេញ ពាណិជ្ជ
Phnom Penh Commercial Bank
Tel: 023 999 500
PPCB
ATM

ធនាគារ ភ្នំពេញ ពាណិជ្ជ
Phnom Penh Commercial Bank

# ធនាគារដែលបង្កើតនូវអនាគតត្រចះត្រចង់របស់កម្ពុជា



# មាតិកា


| | | ទំព័រ |
|---|---|---|
| ១. | ព័ត៌មានរួមអំពីធនាគារ | ២ |
| ១.១ | ប្រវត្តិសង្ខេបធនាគារ | ២ |
| ១.២ | ប្រវត្តិរូបសង្ខេបរបស់ក្រុមប្រឹក្សាភិបាល | ៦ |
| ២. | របាយការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល/នាយកប្រតិបត្តិ | ៧ |
| ៣. | អង្គការលេខ | ១២ |
| ៤. | បណ្ដាញប្រតិបត្តិការ | ១៣ |
| ៥. | អភិបាលកិច្ចសាជីវកម្ម | ១៤ |
| ៦. | សេចក្ដីផ្ដើមរបស់ HSFG | ១៥ |
| ៧. | សេចក្ដីផ្ដើមរបស់ SBI Holdings, Inc. | ២០ |
| ៨. | របាយការណ៍ហិរញ្ញវត្ថុ | ២៤ |
| ៨.១ | របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | ២៥ |
| ៨.២ | របាយការណ៍របស់សវនករឯករាជ្យ | ៣០ |
| ៨.៣ | របាយការណ៍ហិរញ្ញវត្ថុក្រោយសវនកម្ម | ៣២ |
| ៩. | ធនាគារដៃគូ | ៧៥ |

# ព័ត៌មានរួមអំពីធនាគារ

## ប្រវត្តិសង្ខេបធនាគារ

ធនាគារ ភ្នំពេញពាណិជ្ជ បានចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួននៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៨ ដោយទទួលបានអាជ្ញាប័ណ្ណពេញលេញ ជាធនាគារពាណិជ្ជ ពីធនាគារជាតិ នៃកម្ពុជា ។ ភាគហ៊ុនរបស់ ធនាគារ ភ្នំពេញពាណិជ្ជ បានមកពីការរួមបញ្ចូលគ្នារវាង Hyundai Swiss Financial Group និងក្រុមហ៊ុនដៃគូដ៏ទៃទៀតចំនួន ៦០ភាគរយ ដែលមានមូលដ្ឋាននៅប្រទេសកូរ៉េ និង SBI Holdings, Inc. ចំនួន ៤០ភាគរយ ដែលមានមូលដ្ឋាននៅប្រទេសជប៉ុន ។

Hyundai Swiss Financial Group បានចាប់បដិសន្ធិឡើងនៅឆ្នាំ១៩៧១ ដែលជាធនាគារសន្សំប្រាក់ធំជាងគេនៅប្រទេសកូរ៉េ ។

SBI Group មានចំនួន ៧០ក្រុមហ៊ុនផ្សេងៗគ្នា ហើយក្រុមហ៊ុនចម្បងគឺ SBI Holdings, Inc. ដែលបានចុះបញ្ជីក្នុងទីផ្សារភាគហ៊ុនក្រុងតូក្យូ ដោយក្នុងនោះដែរ SBI Holdings, Inc. មានក្រុមហ៊ុនបុត្រសម្ព័ន្ធ ជាង ៨០ក្រុមហ៊ុនផ្សេងទៀត នៅជុំវិញពិភពលោក ដែល ធ្វើអាជីវកម្មហិរញ្ញវត្ថុប្រកបដោយភាពឆ្នៃប្រឌិតដូចជា ក្រុមហ៊ុនវិនិយោគSBI (SBI Investment Co., Ltd.) ជាក្រុមហ៊ុនមូលធនដ៏ធំជាងគេ នៅប្រទេសជប៉ុន និង ក្រុមហ៊ុនមូលប័ត្រ SBI (SBI Securities Co., Ltd.) ជាក្រុមហ៊ុនមូលប័ត្រឈានមុខគេ ។

បន្ទាប់ពីបានបើកដំណើរការជាផ្លូវការមក ធនាគារភ្នំពេញពាណិជ្ជ បានពង្រីកនូវការបំរើសេវាកម្មរបស់ខ្លួន បន្ថែមទៀតដោយបានបើក ឱ្យដំណើរការនូវសាខាទី១របស់ខ្លួន កាលពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ គឺសាខាប៊ីអេស ដែលមានទីតាំងស្ថិតនៅអគារប៊ីអេស មហាវិថីព្រះមុនីវង្ស សង្កាត់មនោរម្យ ខណ្ឌ៧មករា ។ រយៈពេលមួយឆ្នាំក្រោយមកទៀត ធនាគារភ្នំពេញពាណិជ្ជ បានដាក់ឱ្យដំណើរការ នូវសាខាទី២បន្ថែមទៀត ដែលចាប់ផ្តើមពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១ គឺសាខាផ្សារដើមគ ដែលមានទីតាំងស្ថិតនៅអគារលេខ ៧៨ មហាវិថីព្រះមុនីរ៉េត សង្កាត់ទួលស្វាយព្រៃ២ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

### ព័ត៌មាន

| | | |
|---|---|---|
| ធនាគារ | : | ធនាគារភ្នំពេញពាណិជ្ជ |
| កាលបរិច្ឆេទបង្កើត | : | ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៨ |
| លេខចុះបញ្ជី | : | Co. 4898E / 2008 |
| អាសយដ្ឋាន | : | លេខ ៧៦៧-៧៦៩ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ |
| ម្ចាស់ហ៊ុន | : | SBI Holdings, Inc. Japan ៤០ ភាគរយ<br>Hyundai Swiss Savings Bank ៩.៩ ភាគរយ<br>Hyundai Swiss Savings II Bank ៩.៩ ភាគរយ<br>Kyong Ki Growth & Development ៩.៩ ភាគរយ<br>Hidy Investment Co., Ltd ៩.៩ ភាគរយ<br>Mirae Credit Information Service Corp ៣ ភាគរយ<br>Mr. Kim Kwang Jin ៩.៩ ភាគរយ<br>Mr. Kim Jong Min ៧.៥ ភាគរយ |

| | | |
|---|---|---|
| ក្រុមប្រឹក្សាភិបាល | : | លោក គីម យ៉ាងជីន |
| | | លោក អ៊ីជីរ៉ូ សូ |
| ថ្នាក់គ្រប់គ្រង | : | លោក គីម យ៉ាងជីន នាយកប្រតិបត្តិ |
| | | លោក រីយូ ជេយ្យុង នាយកជាន់ខ្ពស់ |
| | | លោក យុន ឆាងហូ នាយកជាន់ខ្ពស់ |
| | | លោក សំណុំ សារុត ប្រធានជាន់ខ្ពស់ផ្នែកសវនកម្មផ្ទៃក្នុង |
| | | លោក ញ៉ក់ គីមស្រួយ ប្រធានជាន់ខ្ពស់ផ្នែកឥណទាន |
| | | លោក ឃិន វិចិត្រ ប្រធានផ្នែកធនធានមនុស្ស និងរដ្ឋបាល |
| | | លោក សែន ចេត្តនា ប្រធានផ្នែកគណនេយ្យ |
| | | លោក ចៅ សុភៈវិរៈ ប្រធានផ្នែកបច្ចេកវិទ្យាព័ត៌មាន |
| | | លោក លី សម្បត្តិ ប្រធានផ្នែកហិរញ្ញប្បទានពាណិជ្ជកម្ម |
| | | អ្នកស្រី ឈរ ឈុនហុង នាយកសាខាប៊ីអេស |
| | | លោក ខុម តាំងស្រ៊ូ នាយកសាខាផ្សារដើមគ |
| ក្រុមហ៊ុនដៃគូ | : | ក្រុមហ៊ុនមូលប័ត្រភ្នំពេញ SBI |
| សវនករ | : | ខេភីអឹមជី ខេមបូឌា ចំកាត់ |

## ធនធានមនុស្សរបស់ធនាគារ

នៅធនាគារភ្នំពេញពាណិជ្ជ យើងទទួលស្គាល់ថាបុគ្គលិកដែលមានសមត្ថភាព ស្មោះត្រង់ និង សមត្ថភាពខ្ពស់ជាធនធាន របស់ធនាគារ និង ជាកំលាំងដ៏ខ្លាំងបំផុត សំរាប់ដំណើរការអាជីវកម្ម ។ ដូច្នេះហើយ យើងប្តេជ្ញាអភិវឌ្ឍន៏ វិជ្ជាជីវៈរបស់ពួកគេតាមរយៈវិធីសាស្រ្តសំខាន់ៗរួមមានការបណ្តុះបណ្តាលអំពីអាកប្បកិរិយាទូទៅ ការបណ្តុះបណ្តាលផ្នែកបច្ចេកទេស បំលាស់ប្តូរមុខងារ និង ការដំឡើងឋានៈ។ បុគ្គលិករបស់យើង ត្រូវបានបណ្តុះបណ្តាលនូវជំនាញ និងភាពវៃឆ្លាតដ៏ជាក់លាក់ និង ដើរតាមគំរូរបស់ថ្នាក់គ្រប់គ្រងដែលមានវិជ្ជាជីវៈខ្ពស់ ។

## ការធ្វើការងារជាក្រុមគឺជាវប្បធម៌របស់យើង

វប្បធម៌នៃការធ្វើការជាក្រុម និងភាពឥតខ្ចោះនៃសេវាកម្មបំរើអតិថិជនគឺជាគន្លឹះឆ្ពោះទៅរកសមិទ្ធិផលដ៏គួរអោយកត់សំគាល់ និងដំណើរការដ៏រឹងមាំរបស់ ធនាគារ ភ្នំពេញពាណិជ្ជ ។

ការធ្វើការជាក្រុមត្រូវបានជំរុញយ៉ាងមុតមាំនិងជាបន្តនៅក្នុងកន្លែងធ្វើការ។ តាមរយៈការសហប្រតិបត្តិការពីគ្រប់នាយកដ្ឋាន លទ្ធផលដែលទទួលបានគឺត្រឹមត្រូវតាមវេលាកំណត់។

## ការបំពេញតំរូវការរបស់អតិថិជនគឺជាជំហានយ៉ាងសំខាន់របស់យើង

ការបំពេញតំរូវការរបស់អតិថិជនត្រូវបានចាត់ទុកជាចំណុចអាទិភាពរបស់ធនាគារ អតិថិជនរបស់យើងជានិច្ចកាល មានការចាប់អារម្មណ៏យ៉ាងខ្លាំង ចំពោះការផ្តល់សេវាកម្មល្អឥតខ្ចោះដោយបុគ្គលិកដែលមានការប្តេជ្ញាខ្ពស់របស់យើង។ គ្រប់ពេលវេលាយើងប្តេជ្ញាចិត្តឆ្ពោះទៅរកសេវាកម្មដែលមានគុណភាពតាមរយៈការយល់ដឹងពីផលិតផល និង អតិថិជនរបស់យើង។

យើងធ្វើការបំរើអតិថិជនរបស់យើងដោយការគោរព ជាពិសេសបុគ្គលិករបស់ធនាគារត្រូវបានដាក់បម្រាមយ៉ាងតឹងរឹង ដោយមិនអនុញ្ញាតអោយបង្កជំលោះ ជាមួយអតិថិជនជាដាច់ខាត ទោះបីជាឋិតនៅក្នុងពេលវេលានិងកាលៈទេសៈណាក៏ដោយ ចំណែកឯការទិតៀន រិះគន់ និងយោបល់របស់អតិថិជន ត្រូវបានទទួលយកដោយរីករាយ ។

## អភិវឌ្ឍន៍ភាពវៃឆ្លាតដើម្បីភាពជោគជ័យជាបន្ត

បុគ្គលិករបស់យើង គឺជាធនធានដ៏មានសារៈសំខាន់ដើម្បីពង្រីកអាជីវកម្ម ហេតុដូច្នេះហើយយើងធ្វើការពិចារណាយ៉ាងយកចិត្តទុកដាក់ក្នុងការវាយតំលៃទៅលើជំនាញដែលចាំបាច់សំរាប់បុគ្គលិកម្នាក់ៗ។ ជាងនេះទៅទៀតយើងគាំទ្រ និងលើកតម្កើងផែនការអភិវឌ្ឍន៍ របស់បុគ្គលិកម្នាក់ៗ ដើម្បីធានាថាពួកគេមានជំនាញពិតប្រាកដដើម្បីបំរើអតិថិជន និង ជួយអោយធនាគារសំរេចគោលបំណងរបស់ខ្លួន។

## និមិត្តសញ្ញាពាណិជ្ជកម្ម

ជាផ្នែកមួយនៃទស្សនៈវិស័យរបស់ធនាគារគឺពង្រីកអោយបានជាអតិបរមានូវតំលៃនៃនិមិត្តសញ្ញា ធនាគារបានផ្លាស់ប្តូរនិមិត្តសញ្ញាពាណិជ្ជកម្មរបស់ខ្លួន នៅខែតុលា ឆ្នាំ២០០៩ ដើម្បីផ្តល់ជាចំណាប់អារម្មណ៍សំរាប់សាធារណៈជន ។និមិត្តសញ្ញាពាណិជ្ជកម្មថ្មីត្រូវបានរចនាយ៉ាងច្បាស់លាស់ ដែលបង្ហាញពីភាពរឹងមាំ និង ការសហការគ្រប់ផ្នែកទាំងអស់ ។



## ការចូលរួមសកម្មភាពសង្គម

ជាមួយនឹងការប្តេជ្ញាចិត្ត ដើម្បីអនាគតភ្លឺស្វាងដល់ប្រទេសកម្ពុជា ធនាគារភ្នំពេញពាណិជ្ជបានចូលរួមយ៉ាងសកម្ម ជាមួយនឹងសកម្មភាពសប្បុរសធម៌ ។ ប្រាក់ចំណេញមួយផ្នែករបស់ធនាគារ នឹងវិលត្រលប់ទៅជាជំនួយសំរាប់ជួយដល់ សហគមន៏ សង្គម និងស្ថាប័នសប្បុរសធម៌ដទៃទៀត ក្នុងប្រទេសកម្ពុជា ។ ដោយសារសង្គ្រាមស៊ីវិល មានជនពិការ ជនអនាថា ជនគ្មានទីលំនៅ និងស្ត្រីមេម៉ាយ រាប់ពាន់នាក់ ដែលកំពុងតែត្រូវការជំនួយ និងការគាំទ្រ ។

ក្នុងក្តីសង្ឃឹមថា ជំនួយរបស់យើងនឹងអាចជួយដល់ការរស់នៅរបស់ប្រជាជន ដែលទទួលនូវការឈឺចាប់ ឱ្យបានប្រសើរ យើងបានផ្តល់នូវជំនួយជាថវិកាជូនដល់មជ្ឈមណ្ឌលជនពិការ ដែលមានឈ្មោះថា *"បន្ទាយព្រាប"* ដែលមានទីតាំងស្ថិតនៅស្រុកអង្គស្នួល ខេត្តកណ្តាល ដើម្បីឱ្យមជ្ឈមណ្ឌលនេះបានបន្តនូវដំណើរការទៅមុខជាបន្តទៀត សំរាប់ជួយដល់ជន ដែលបាត់បង់សមត្ថភាពឱ្យមាន ជំនាញមួយយ៉ាងពិតប្រាកដ ដើម្បីឱ្យពួកគេអាចចិញ្ចឹមជីវិតបាន ដោយខ្លួនឯងនៅពេលខាងមុខ ។

យើងនឹងបន្តនូវការជួយឧបត្ថម្ភនេះ ទៅដល់សហគមន៏ សង្គម និងស្ថាប័នមនុស្សធម៌នានា នៅក្នុងប្រទេសកម្ពុជានៅពេលខាងមុខ ជាបន្តទៀត ។

## ការផ្តល់អំណោយរបស់ ធនាគារភ្នំពេញពាណិជ្ជ ដល់មជ្ឈមណ្ឌលជនពិការ

*ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១០ មជ្ឈមណ្ឌល "បន្ទាយព្រាប" ស្រុកអង្គស្នួល ខេត្តកណ្តាល*



*ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១១ មជ្ឈមណ្ឌល "បន្ទាយព្រាប" ស្រុកអង្គស្នួល ខេត្តកណ្តាល*



## ប្រវត្តិរូបរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលត្រូវបានតែងតាំងដោយភាគទុនិក ដើម្បីធ្វើសកម្មភាពតំណាងឱ្យពួកគេផ្ទាល់ ។ សមាជិកក្រុមប្រឹក្សាភិបាល មានចំនួន ២នាក់ គឺលោក Kim Yang Jin និងលោក Eiichiro So ។ ក្រុមប្រឹក្សាភិបាល ជួបប្រជុំគ្នាយ៉ាងទៀងទាត់ ជាពិសេសដើម្បីត្រួតពិនិត្យការប្រព្រឹត្តទៅ និង ការរីកចំរើននៃដំណើរការអាជីវកម្ម និង បញ្ហាទាំងឡាយដែលទាមទារសេចក្តីសំរេចពីក្រុមប្រឹក្សាភិបាល ។

### លោក គីម យ៉ាងជីន
ប្រធានក្រុមប្រឹក្សាភិបាល ជនជាតិកូរ៉េ



**កំរិតវប្បធម៌**

អនុបណ្ឌិតវិទ្យាសាស្ត្រអចលនទ្រព្យ ពីសាកលវិទ្យាល័យ Konkuk ក្រុងសេអ៊ូល ប្រទេសកូរ៉េ

**បទពិសោធន៏ការងារ**

បទពិសោធន៏ការងាររយៈពេល៣០ឆ្នាំ ជាមួយធនាគារ គូកមីន, ប្រទេសកូរ៉េ
នាយករង នាយកដ្ឋានអាជីវកម្មអន្តរជាតិ
នាយករង ធនាគារគូកមីន សាខាក្រុងញូវយ៉ក
នាយក នាយកដ្ឋានប្រតិបត្តិការប្តូរប្រាក់
នាយក នាយកដ្ឋានសាជីវកម្មធនាគារ
នាយក នាយកដ្ឋានធនាគារខ្នាតមធ្យម
នាយក នាយកដ្ឋានគ្រប់គ្រងឥណទាន
ប្រធាន នាយកដ្ឋានគ្រប់គ្រងតំបន់ភាគខាងលិច និងខាងកើត
នាយកប្រតិបត្តិរង ក្រុមហ៊ុន KB Real Estate Trust



### លោក អ៊ីជីរ៉ូ ស្វូ
នាយក ជនជាតិជប៉ុន

**កំរិតវប្បធម៌**

អនុបណ្ឌិត ផ្នែកហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ Hitotsubashi ទីក្រុងតូក្យូ ប្រទេសជប៉ុន
បរិញ្ញាបត្រ ភាសាកូរ៉េ ពីសាកលវិទ្យាល័យ Yonsei ទីក្រុងសេអ៊ូល ប្រទេសកូរ៉េ
បរិញ្ញាបត្រគណនេយ្យ ពីសាកលវិទ្យាល័យ Chou ទីក្រុងតូក្យូ ប្រទេសជប៉ុន

**បទពិសោធន៏ការងារ**

នាយកប្រតិបត្តិរង SBI Ven Capital Pte., Ltd. ប្រទេសសិង្ហបូរី
នាយក នាយកដ្ឋានអាជីវកម្មក្រៅប្រទេស នៃ SBI Holdings
នាយកប្រតិបត្តិរងនៃ Sumitomo Mitsui Banking Corporation សាខាក្រុងសេអ៊ូល ប្រទេសកូរ៉េ

# របាយការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល/នាយកប្រតិបត្តិ



ជូនចំពោះអតិថិជន ភាគទុនិក និងមិត្តភក្តិរបស់ ធនាគារ ភ្នំពេញពាណិជ្ជ ទាំងអស់ !

ជាទូទៅ ស្ថានភាពសេដ្ឋកិច្ច របស់ប្រទេសកម្ពុជាមានលក្ខណៈល្អប្រសើរ គឺមានការកើនលើសពីឆ្នាំកន្លងមក ។ ហើយការកើនឡើងនេះបានមក ពីការកើនឡើងលើវិស័យកសិកម្ម ផលិតកម្ម សំណង់ ទេសចរណ៍ និង សេវាកម្ម ។ បើទោះបីជាពិភពលោកទាំងមូលទទួលរងនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ពីវិបត្តិជាសកលក៏ដោយ ក៏ស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា នៅរក្សាបាននូវភាពល្អប្រសើរជាលំដាប់ លើវិស័យកសិកម្ម ការអភិវឌ្ឍន៍ជាមូលដ្ឋានលើវិស័យមិនមែនកសិកម្ម ស្ថិរភាពនយោបាយ ការកើនឡើងនូវជំនួយអភិវឌ្ឍន៍ផ្សេងៗ ព្រមទាំងការកើនឡើងនូវការវិនិយោគ ដោយផ្ទាល់ពីបរទេស ។ ផលិតផលក្នុងស្រុកសរុប (GDP) សំរាប់ឆ្នាំ២០១០ មានការកើនឡើងចំនួន ៥ភាគរយ រីឯការព្យាករណ៍សំរាប់ឆ្នាំ២០១១ នេះ រដ្ឋាភិបាលរំពឹងទុកថា (GDP) និងមានការកើនឡើងចំនួន ៦ភាគរយ ។

វិស័យធនាគារ និងហិរញ្ញវត្ថុនៅតែរក្សាបាននូវស្ថិរភាព និងគុណភាពល្អដដែល ។ ធនាគារជាតិនៃកម្ពុជា បានបន្តធ្វើឱ្យកាន់តែមាន ជំនឿជាក់ នៅក្នុងវិស័យធនាគារ ដោយបានចេញប្រកាស និងបទបញ្ញត្តិមួយចំនួន ដើម្បីរៀបចំឱ្យមានមូលដ្ឋានគ្រឹះនៃដើមទុនរបស់ ស្ថាប័នហិរញ្ញវត្ថុ ។ ក្នុងនោះរួមមាន ការបង្កើនកាតព្វកិច្ចដើមទុនអប្បបរមា របស់ធនាគារពាណិជ្ជ រហូតដល់ ១៥០ពាន់លានរៀល (ប្រមាណ ៣៧,៥លានដុល្លារអាមេរិក) ។ វិធានការទាំងនេះពិតជាមានសារសំខាន់ណាស់ ចំពោះការរក្សានូវស្ថិរភាពសេដ្ឋកិច្ចរបស់ ប្រទេសដែលពឹងផ្អែកទៅលើសាច់ប្រាក់ជាធំ ។

## សមិទ្ធិផល

ធនាគារភ្នំពេញពាណិជ្ជ បានបង្ហាញពីប្រាក់ចំណូលសរុបប្រចាំឆ្នាំចំនួន ៣.៦១៥.២៤១ដុល្លារអាមេរិក ដែលប្រាក់ចំណេញសុទ្ធមានចំនួន ៥៩៤.១៨០ដុល្លារអាមេរិក នៅឆ្នាំ២០១០ ដែលតួលេខនេះ មានការកើនឡើងចំនួន ៣៩,៥០ភាគរយ ពីឆ្នាំកន្លងទៅ ហើយនេះជា តួលេខមួយល្អបើប្រៀបធៀប ទៅនឹងសេដ្ឋកិច្ចសកលនាពេលបច្ចុប្បន្ន ។ ចំពោះប្រាក់កម្ចីសរុបកើនឡើង ៤៧,១៩ភាគរយ ស្មើនឹង ២៤,៧លានដុល្លារអាមេរិក ចាប់ពីដំណាច់ឆ្នាំ២០១០ ។ ទ្រព្យសកម្មសរុបកើនឡើង ៤១,៦៥ភាគរយ ស្មើនឹង ៥៨,៣លានដុល្លារអាមេរិក និងប្រាក់បញ្ញើកើនឡើង ១៩,៣លានដុល្លារអាមេរិក ។ ទំនុកចិត្តរបស់អតិថិជន ដែលបានផ្តល់ឱ្យ និងកំរិតខ្ពស់ នៃសន្ទនីយភាពធ្វើឱ្យ ធនាគារអាចបញ្ចេញមូលនិធិ ទៅក្នុងសេដ្ឋកិច្ចកម្ពុជា តាមរយៈការកើនឡើងនូវតំរូវការឥណទាន នៅក្នុងប៉ុន្មានខែចុងក្រោយនេះ ។ អនុបាតសាធនភាពរបស់ធនាគារ ស្ថិតក្នុងចំនួន ៣០,០៤ភាគរយ ដែលចំនួននេះ លើសពីកំរិតតម្រូវការរបស់ធនាគារជាតិនៃកម្ពុជា ។ ភាពខ្លាំងខាងហិរញ្ញវត្ថុរបស់ធនាគារ និងមូលធនគ្រប់គ្រាន់ បានឆ្លុះបញ្ចាំងពីមូលដ្ឋានគ្រឹះដ៏រឹងមាំរបស់ធនាគារ និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការបំរើសេវាឈានមុខគេ ជូនអតិថិជនទៅថ្ងៃអនាគត ។

## ទស្សនវិស័យ

ខណៈពេលវេលាមិនទាន់អំណោយផលនៅឡើយចំពោះប្រទេសកម្ពុជា និងធនាគារភ្នំពេញពាណិជ្ជ យើងមានជំនឿចិត្តថា ភាពខ្លាំង និងភាពមិនងាករេរបស់ធនាគារ នឹងផ្តល់ទំនុកចិត្តដល់ដៃគូទាំងអស់ដើម្បីបន្តនូវអាត្រាកំណើនថេរ ជាមួយអតិថិជន និងប្រទេសជាតិទាំងមូល ក្នុងដំណើរប្រកបដោយចិរភាពទៅឆ្នាំខាងមុខ ។

យើងខ្ញុំនឹងបន្តពង្រីកបណ្តាញសាខា ហេដ្ឋារចនាសម្ព័ន្ធ បង្កើនមូលដ្ឋានប្រាក់បញ្ញើ និងផ្តល់ជូននូវផលិតផល និងសេវាកម្មថ្មីៗ ដើម្បីឆ្លើយតបតាមបត្រូវការរបស់អតិថិជនរបស់យើងខ្ញុំ ។ ក្រៅពីនេះ យើងខ្ញុំនឹងបន្តពង្រឹងប្រព័ន្ធ គ្រប់គ្រងហានិភ័យ និងលើកកំពស់ប្រសិទ្ធភាពដំណើរការគ្រប់គ្រងប្រតិបត្តិការផ្ទៃក្នុងបន្ថែមទៀត ។ ធនាគារនឹងបន្តលើកកំពស់ ទទួលយក និងអនុវត្តនូវអភិបាលកិច្ចល្អ ដែលជាមូលដ្ឋានចាំបាច់ សំរាប់កំណើនចិរភាព ។

## សីលធម៌ក្នុងការគ្រប់គ្រង

ធនាគារបន្តអភិវឌ្ឍន៍ធនធានមនុស្សយ៉ាងសកម្ម ។ វគ្គហ្វឹកហ្វឺនចំពោះថ្នាក់គ្រប់គ្រង និងបុគ្គលិក ត្រូវបានអភិវឌ្ឍន៍ជាបន្តបន្ទាប់ក្នុងឆ្នាំ២០១០ និងជាអាទិភាពចំបង សំរាប់ឆ្នាំ២០១១ នេះ ក្រោមការគ្រប់គ្រងប្រកបដោយក្រមសីលធម៌ ។ ជាងនេះទៅទៀត សីលធម៌ និង ចរិយាមាយាទ គឺជាផ្នែកមួយយ៉ាងសំខាន់ នៃភាពរឹងមាំក្នុងការគ្រប់គ្រង ។ សីលធម៌ ជាកត្តាដែលមានសារសំខាន់បំផុត ដែលជាផ្លូវដ៏ទូលាយសំរាប់ឆ្ពោះទៅកាន់ប្រភពនៃព័ត៌មាន និង ឱកាសនៃការធ្វើអាជីវកម្មផ្សេងៗ ជាងពេលណាណាទាំងអស់ ។ ហេតុ ដូច្នេះហើយ ខ្ញុំនឹងរក្សានូវជំនឿរបស់ខ្ញុំ ដោយការអនុវត្តនូវការគ្រប់គ្រងប្រកបដោយ ក្រមសីលធម៌ ការខិតខំប្រឹងប្រែង ភាពសច្ចៈ ទៀងត្រង់ ដើម្បីឱ្យប្រតិបត្តិការធនាគារ និងការបំរើអតិថិជន មានការរីកចំរើនទៅមុខជាលំដាប់ ។

## ការទទួលស្គាល់

ខ្ញុំមានក្តីសោមនស្សជាអតិបរមា និងសូមសំដែងនូវការដឹងគុណដ៏ស្មោះជូនដល់ភាគទុនិក មិត្តភក្តិ អតិថិជន ទីប្រឹក្សាជំនាញ និងនិយ័តករទាំងអស់ ដែលបានគាំទ្រ និងផ្តល់ជូនយើងខ្ញុំនូវទិសដៅ និងមគ្គុទេសក៏ ចំពោះប្រព័ន្ធធនាគារនៅគ្រប់កាលៈទេសៈ ។

ជាទីបញ្ចប់ ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ដល់និយោជិតគ្រប់ជាន់ថ្នាក់ទាំងអស់ដែលបានខិតខំ បូជាកំលាំងកាយ កំលាំងចិត្ត ភក្តីភាព និងប្រឹងប្រែងក្នុងការបំពេញភារកិច្ចជូនធនាគារ ។ ខ្ញុំសង្ឃឹម និងមានជំនឿយ៉ាងមុតមាំថា ភាពជោគជ័យនឹងកើតមានជាដរាបនាឆ្នាំខាងមុខ ចំពោះអ្នកទាំងអស់ និងសូមបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំនេះ ដល់អ្នកទាំងអស់គ្នា ។



គីម យ៉ាងជីន

**នាយកប្រតិបត្តិ**

# ផលិតផល និងសេវាកម្ម

**• ប្រាក់បញ្ញើ**
- គណនីចរន្ត
- គណនីសន្សំ
- ប្រាក់បញ្ញើមានកាលកំណត់
- ប្រាក់បញ្ញើផ្សេងៗ

**• ប្រាក់កម្ចី**
- ឯកត្តជន
- សាជីវកម្ម
- ឥណទានបញ្ចាំ

**• ពាណិជ្ជកម្មអាស្រ័យកម្រៃ**
- សេវាផ្ទេរប្រាក់ក្នុងប្រទេស និងជាអន្តរជាតិ
- លិខិតឥណទាន
- ការពិគ្រោះយោបល់ ( អចលនទ្រព្យ IPO )
- ការចេញសញ្ញាប័ណ្ណ

**• ធនាគារសាជីវកម្ម**
- ការអោយខ្ចីជារូបិយប័ណ្ណបរទេស
- ឥណទានសំរាប់រោងចក្រ
- លិខិតឥណទាននិងការធានា




*សាលបំរើអតិថិជន សាខាប៊ឹងកេង*



*សាលបំរើអតិថិជន សាខាផ្សារដើមគ*

សេវាកម្មល្អបំផុត សុវត្ថិភាពខ្ពស់បំផុត

ដំណោះស្រាយប្រសើរបំផុត



# អតិថិជន គឺជាផ្កា

**ពិធីសម្ពោធ ធនាគារភ្នំពេញពាណិជ្ជ សាខាបឹងកេងកង**

*ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១០*



**ពិធីសម្ពោធ ធនាគារភ្នំពេញពាណិជ្ជ សាខាផ្សារដើមគ**

*ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១១*



# អង្គការលេខ




ចំណាំ: អង្គការលេខនេះបង្កើតឡើងនៅឆ្នាំ២០១១

# បណ្តាញប្រតិបត្តិការ



# អភិបាលកិច្ចសាជីវកម្ម

ដោយសារមានការផ្តោតអារម្មណ៍យ៉ាងខ្លាំងនាពេលថ្មីៗនេះទៅលើបញ្ហាអភិបាលកិច្ចសាជីវកម្ម ធនាគារ ភ្នំពេញពាណិជ្ជ ទទួលស្គាល់ពីតំរូវការដើម្បីអោយមានអភិបាលកិច្ចត្រឹមត្រូវ ដែលពាក់ព័ន្ធនឹងគ្រប់ទំនាក់ទំនងទាំងអស់រវាងថ្នាក់ដឹកនាំធនាគារ ម្ចាស់ភាគហ៊ុន និងដៃគូពាក់ព័ន្ធ។ ធនាគារ ភ្នំពេញពាណិជ្ជ ផ្តល់ចំណាប់អារម្មណ៍ដល់ដៃគូពាក់ព័ន្ធចំពោះអភិបាលកិច្ចសាជីវកម្មដ៏ត្រឹមត្រូវរួមមានៈ

### បង្កើតទិសដៅយុទ្ធសាស្រ្ត និងកំណត់គុណតំលៃសាជីវកម្មដែលត្រូវដឹងទូទាំងធនាគារ

ក្រុមប្រឹក្សាភិបាលធានាថា អ្នកដឹកនាំជាន់ខ្ពស់អនុវត្តគោលការណ៍ដែលទប់ស្កាត់( ឬកំណត់យ៉ាងតឹងរឹង) សកម្មភាពនិងទំនាក់ទំនងទាំងឡាយណាធ្វើអោយខូចគុណភាពអភិបាលកិច្ចសាជីវកម្ម មានដូចជា ជម្លោះផលប្រយោជន៍ និងការផ្តល់ផលពិសេសចំពោះភាគីពាក់ព័ន្ធ និងអង្គភាពផ្សេងៗទៀត។

### កំណត់ និងអនុវត្តព្រំដែនច្បាស់លាស់នៃការទទួលខុសត្រូវ និងទំនួលខុសត្រូវទូទាំងធនាគារ

ក្រុមប្រឹក្សាភិបាលកំណត់យ៉ាងច្បាស់ពីសមត្ថកិច្ច និងការទទួលខុសត្រូវសំខាន់ៗសម្រាប់ពួកគេក៏ដូចជាថ្នាក់ដឹកនាំជាន់ខ្ពស់ផង ដែរ ។ ពួកគេក៏ទទួលស្គាល់ដែរថា ភាពមិនជាក់លាក់នៃព្រំដែនការទទួលខុសត្រូវ ឬការយល់ច្រលំនៃការទទួលខុសត្រូវ ដ៏សន្ទឹកសន្ធាប់ពេក អាចធ្វើអោយ បញ្ហាកាន់តែធ្ងន់ធ្ងរឡើងដោយធ្វើអោយដំណោះស្រាយយឺត រឺគ្មានប្រសិទ្ធភាព។ ថ្នាក់ដឹកនាំជាន់ខ្ពស់ទទួលខុសត្រូវបង្កើតឋានានុក្រមទំនួលខុសត្រូវសម្រាប់បុគ្គលិក។

### ធ្វើអោយប្រាកដថាសមាជិកក្រុមប្រឹក្សាភិបាលមានសមត្ថភាពគ្រប់គ្រាន់សម្រាប់មុខដំណែងរបស់ពួកគេ យល់ច្បាស់ពីតួនាទីរបស់ពួកគេក្នុងអភិបាលកិច្ចសាជីវកម្មហើយមិននៅក្រោមឥទ្ធិពលជ្រុលពេកពីថ្នាក់ដឹកនាំ ឬភាគីខាងក្រៅ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវចុងក្រោយចំពោះប្រតិបត្តិការផ្សេងៗនិងភាពត្រឹមត្រូវផ្នែកហិរញ្ញវត្ថុចំពោះធនាគារ។ ហេតុនេះ ក្រុមប្រឹក្សាភិបាល ត្រូវវាយតំលៃចំពោះការអនុវត្តរបស់ខ្លួនដោយកំណត់ពេលច្បាស់លាស់ ដោយកំណត់ចំណុចខ្សោយដែលមានស្រាប់ និង បើអាចទៅរួចត្រូវចាត់វិធានការកែតំរូវអោយបានសមរម្យ។

### ធានាថាមានការគ្រប់គ្រងត្រឹមត្រូវដោយថ្នាក់ដឹកនាំជាន់ខ្ពស់

ថ្នាក់ដឹកនាំជាន់ខ្ពស់ ធនាគារភ្នំពេញពាណិជ្ជ ជាសមាសភាពសំខាន់ចំពោះអភិបាលកិច្ចសាជីវកម្ម ។ ចំណែកឯក្រុមប្រឹក្សាភិបាល ផ្តល់ការត្រួតពិនិត្យ តាមដានចំពោះថ្នាក់ដឹកនាំជាន់ខ្ពស់។

### ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពការងារដែលធ្វើដោយសវនកម្មផ្ទៃក្នុង និងសវនកម្មឯករាជ្យ ដោយទទួលស្គាល់តួនាទីគ្រប់គ្រងសំខាន់ដែលពួកគេផ្តល់អោយ

ក្រុមប្រឹក្សាភិបាលដឹង និងទទួលស្គាល់ថាសវនកម្មផ្ទៃក្នុង និងសវនកម្មឯករាជ្យជាភ្នាក់ងារសំខាន់របស់ពួកគេ ជាពិសេស ក្រុមប្រឹក្សាភិបាល អាចប្រើប្រាស់ការងារសវនកម្មជាការត្រួតពិនិត្យឯករាជ្យមួយ ចំពោះព័ត៌មានដែលបានទទួលពីថ្នាក់ដឹកនាំលើការងារប្រតិបត្តិការ និង ដំណើរការរបស់ធនាគារ។

### ធ្វើអោយប្រាកដថាវិធីសាស្រ្តក្នុងការទូទាត់ត្រឹមត្រូវតាមតម្លៃក្រមសីលធម៌ ទិសដៅ យុទ្ធសាស្រ្ត និងបរិយាកាសគ្រប់គ្រងរបស់ធនាគារ

អនុវត្តអភិបាលកិច្ចសាជីវកម្មក្នុងលក្ខណៈតម្លាភាព ធនាគារ ភ្នំពេញពាណិជ្ជ ប្តេជ្ញាអនុវត្តអភិបាលកិច្ចសាជីវកម្ម ប្រកបដោយតម្លាភាព ។

# សេចក្តីផ្តើមរបស់ HSFG

ជាមួយនឹងអត្រាកំណើនប្រចាំឆ្នាំជាក់ស្តែងសម្ព័ន្ធក្រុមហ៊ុន ហ៊ីយ៉ាន់ដាយស្វីស (Hyundai Swiss Financial Group) បានក្លាយជាគ្រឹះស្ថានហិរញ្ញវត្ថុនាំមុខគេ ដោយសារតែប្រព័ន្ធវិនិយោគបែបវិទ្យាសាស្ត្រប្លែកពីគេរបស់ធនាគារនេះដែលត្រូវបានអនុវត្តដោយផ្អែកទៅលើទិន្នន័យវិនិយោគជាក់ស្តែងនិងយុទ្ធសាស្ត្រច្នៃប្រឌិតដោយយកចិត្តទុកដាក់។ សម្ព័ន្ធក្រុមហ៊ុន ហ៊ីយ៉ាន់ដាយស្វីស បង្ហាញនូវគំនិតផ្តួចផ្តើម ដោយព្យាករណ៍ទុកជាមុន និងត្រៀមផ្លាស់ប្តូរ ដោយឆ្លើយតបយ៉ាងសកម្មទៅនឹងបរិយាកាសហិរញ្ញវត្ថុដែលផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ។ សម្ព័ន្ធក្រុមហ៊ុន ហ៊ីយ៉ាន់ដាយស្វីស បានក្លាយជាក្រុមហ៊ុនហិរញ្ញវត្ថុសកលដោយទទួលបានប្រាក់ចំណេញខ្ពស់ពីផលិតផលហិរញ្ញវត្ថុផ្សេងៗគ្នា។

## ព័ត៌មាន

ទស្សនវិស័យ ឆ្នាំ២០១៥ "ជាប្រភពហិរញ្ញវត្ថុដ៏ល្អ ដែលតែងតែនៅជិតអ្នក" ជាក្រុមហ៊ុនហិរញ្ញវត្ថុដ៏ទូលំទូលាយ លេខ១ របស់ប្រទេសកូរ៉េ

## សមិទ្ធផល




## យុទ្ធសាស្ត្រគ្រប់គ្រង

Hyundai Swiss Financial Group (HSFG) មានសមត្ថភាពយ៉ាងខ្លាំងក្នុងការព្យាករណ៍ការផ្លាស់ប្តូរបានយ៉ាងល្អ មុនអ្នកដទៃដោយផ្អែកលើមូលដ្ឋានយ៉ាងត្រឹមត្រូវរបស់យើង ក្នុងការវិភាគ ស្រាវជ្រាវ តាមតួលេខនៃស្ថិតិ ។

យើងនឹងវិនិយោគលើយុទ្ធសាស្ត្រគ្រប់គ្រងផ្ទាល់របស់ខ្លួនដើម្បីទទួលបានចំណេញយ៉ាងច្រើនពីបរិយាកាសហិរញ្ញវត្ថុកំពុងវិវត្តន៍ដែលមិនធ្លាប់មានពីមុន។

### ការគ្រប់គ្រងហានិភ័យ
- គ្រប់គ្រងស្ថិតិនិងភវនីយភាព
- ជៀសវាងកំណើនបរិមាណ
- បង្កើតគំរូកំណើនខ្ពស់ទី១/ផលប័ត្រ

### ការគ្រប់គ្រងផ្តោតលើតម្លៃ
- លើកស្ទួយម៉ាជីនពិតប្រាកដ
- មានបំណងគ្រប់គ្រងតម្លៃឱ្យបានសមរម្យបំផុត
- បញ្ជាក់ទស្សនៈនៃប្រាក់ចំណេញអោយបានច្បាស់

### និមិត្តសញ្ញាដែលគួរទុកចិត្ត
- ផ្តោតទៅលើភាពខុសប្លែកគ្នានៃនិមិត្តសញ្ញា
- លើកកំពស់ និងគាំទ្រទាំងទំនុកចិត្តជាតិ និងអន្តរជាតិ
- សាងសង់មជ្ឈមណ្ឌល PB ឱ្យបានល្អបំផុត

### ការពង្រីកបណ្តាញប្រាក់ចំណេញ
- បង្កើតប្រភពចំណូលអោយកាន់តែច្រើន
- បង្កើតផែនការយុទ្ធសាស្ត្រប្រកបដោយចីរភាព
- បង្កើតផលិតផលថ្មីនៅក្នុងទីតាំងថ្មី
- ពង្រីកពាណិជ្ជកម្មក្នុងការអនុវត្តន៍ព័ត៌មានវិទ្យា

## ប្រវត្តិកកើត HSFG

### ធនាគារសន្សំប្រាក់ ហ៊ីយ៉ាន់ដាយ ស្វីស

| | |
|---|---|
| ១៩៧១.១០ | បង្កើតក្រុមហ៊ុន |
| ១៩៩៩.០៦ | លោក គីម ក្វាងជីន ឡើងកាន់តំណែងជាប្រធានក្រុមហ៊ុន |
| ១៩៩៩.០៩ | ឈ្មោះក្រុមហ៊ុនត្រូវបានប្តូរទៅជា Hyundai Credit Union |
| ២០០០.០៤ | ទិញយកក្រុមហ៊ុន Gangnam Credit Union |
| ២០០០.០៨ | ឈ្មោះក្រុមហ៊ុនត្រូវបានប្តូរទៅជា Hyundai Swiss Credit Union |
| ២០០២.០៣ | ឈ្មោះក្រុមហ៊ុនត្រូវបានប្តូរទៅជា Hyundai Swiss Savings Bank |
| ២០០៦.១២ | បើកសម្ពោធសាខាស្ថានីយ៍ Gangnam និងសាខា Olympic |
| ២០០៧.០២ | បើកសម្ពោធសាខា Myeongdong |
| ២០០៨.០៤ | បើកសម្ពោធសាខា Yongsan និងសាខាស្ថានីយ៍ Mokdong |

### ធនាគារសន្សំប្រាក់ ហ៊ីយ៉ាន់ដាយ ស្វីស ២

| | |
|---|---|
| ១៩៧២.០៦ | បង្កើតក្រុមហ៊ុន |
| ១៩៨៥.០៥ | ឈ្មោះក្រុមហ៊ុនត្រូវបានប្តូរទៅជា Gangnam Mutual Credit Union |
| ២០០០.០៤ | ទិញយកក្រុមហ៊ុន Hyundai Credit Union |
| ២០០០.០៨ | ឈ្មោះក្រុមហ៊ុនត្រូវបានប្តូរទៅជា Hyundai Swiss 2 Credit Union |
| ២០០២.០៣ | ឈ្មោះក្រុមហ៊ុនត្រូវបានប្តូរទៅជា Hyundai Swiss 2 Savings Bank |
| ២០០៦.០១ | បើកសម្ពោធសាខាស្ថានីយ៍ Isu |
| ២០០៨.០៥ | បើកសម្ពោធសាខាស្ថានីយ៍ Nowon និងសាខា Miasamgeori |

### ធនាគារសន្សំប្រាក់ ហ៊ីយ៉ាន់ដាយ ស្វីស ៣

| | |
|---|---|
| ១៩៧៣.០១ | បង្កើតក្រុមហ៊ុន |
| ២០០៨.១១ | ទិញយកក្រុមហ៊ុន Jungbu Mutual Savings Bank |
| | ឈ្មោះក្រុមហ៊ុនត្រូវបានប្តូរទៅជា Hyundai Swiss 3 Savings Bank |
| ២០០៨.១២ | បើកសម្ពោធសាខា Bundang |
| ២០០៩.០១ | បើកសម្ពោធសាខា Ilsan |
| ២០០៩.០២ | បើកសម្ពោធសាខាស្ថានីយ៍ Daechi |

### ធនាគារសន្សំប្រាក់ ហ៊ីយ៉ាន់ដាយ ស្វីស ៤

| | |
|---|---|
| ២០០៧.១០ | បង្កើតនាយកដ្ឋានផែនការ និងហិរញ្ញវត្ថុ |
| ២០០៩.០៩ | ទិញយកក្រុមហ៊ុន Yea Hanwool Savings Bank |
| | ឈ្មោះក្រុមហ៊ុនត្រូវបានប្តូរទៅជា Hyundai Swiss 4 Savings Bank |

## រង្វាន់ដែលទទួលបាន

**ពានរង្វាន់ឆ្នើម ប្រចាំឆ្នាំ២០០៧ សំរាប់គំនិតច្នៃប្រឌិតថ្មី រង្វាន់ពីនាយករដ្ឋមន្ត្រី**

**រៀបចំដោយ:** សភាពាណិជ្ជកម្ម និង ឧស្សាហកម្មកូរ៉េ

**ផ្នែក:** រង្វាន់នាយករដ្ឋមន្ត្រី

**សិក្សាទៅលើ:** ការចាប់អារម្មណ៍ ជាសាធារណ: និងគំនិតច្នៃប្រឌិតថ្មី

**អ្នកទទួលរង្វាន់:** Hyundai Swiss

**ពានរង្វាន់សំរាប់ នាយកប្រតិបត្តិឆ្នើមប្រចាំទស្សនាវដ្តី Forbes ឆ្នាំ២០១០**

**រៀបចំដោយ:** Forbes Korea

**ផ្នែក:** គ្រប់គ្រងហិរញ្ញវត្ថុសកល

**សិក្សាទៅលើ:** សមត្ថភាពនាយកប្រតិបត្តិ ការចូលរួមចំណែក និង ស្នាដៃក្នុងការគ្រប់គ្រងចាត់ចែង ជាលក្ខណ:សកល

**អ្នកទទួលរង្វាន់:** Hyundai Swiss, Deutsche Bank, BC Card, ។ល។

**ពានរង្វាន់ឆ្នើម ប្រចាំឆ្នាំ២០១០ សំរាប់ការអនុវត្តយុទ្ធសាស្ត្រ BSC ប្រចាំប្រទេសកូរ៉េ**

**រៀបចំដោយ:** Wesley Quest/ Korea Economic Daily

**ផ្នែក:** ការអនុវត្តរបស់ស្ថាប័នឯកជនល្អបំផុត ទៅលើយុទ្ធសាស្ត្រ BSC ក្នុងប្រទេសកូរ៉េ

**សិក្សាទៅលើ:** សំភារ: ការសំភាសន៍ ការស្ទាបស្ទង់ ការត្រួតពិនិត្យដល់ទីកន្លែង ការស៊ើបអង្កេត

**អ្នកទទួលរង្វាន់:** Hyundai Swiss, Ministry of Public Administration, World Vision, ។ល។

## បណ្តាញប្រតិបត្តិការរបស់ HSFG

### HYUNDAI SWISS SAVINGS BANK

ជាធនាគារមួយដែលតែងតែនៅជិតអ្នក

Hyundai Swiss Savings Bank

បន្តកើនឡើងនៅក្នុងបរិយាកាសហិរញ្ញវត្ថុផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ។



### HYUNDAI SWISS ASSET MANAGEMENT

នាំមុខទៅលើគំរូហិរញ្ញវត្ថុថ្មី

យើងនឹងចាប់យកនូវអត្ថប្រយោជន៍ ដោយការប្រើប្រាស់ នូវប្រព័ន្ធវិនិយោគបែបវិទ្យាសាស្ត្រ និងធនធានមនុស្សប្រកបដោយសមត្ថភាព ។

### HYUNDAI SWISS II, III, IV SAVINGS BANK

ជាដៃគូផ្នែកហិរញ្ញវត្ថុដែលគួរឱ្យទុកចិត្ត

ដោយប្រមើលមើលទុកជាមុននូវការផ្លាស់ប្តូរ និងរើសយកប្រព័ន្ធវិនិយោគដែលឈានមុខគេ ហើយជានិច្ចកាលយកចិត្តទុកដាក់ចំពោះអតិថិជនរបស់យើង ។

### PHNOM PENH COMMERCIAL BANK

ជាធនាគារបរទេសដ៏ល្អបំផុត

Hyundai Swiss Savings Bank

ដែលលោតផ្លោះទៅជា ក្រុមហ៊ុនហិរញ្ញវត្ថុទូទៅមួយឥឡូវនេះយើងកំពុងឆ្ពោះទៅកាន់ពិភពលោក ។

## ៤ ការិយាល័យកណ្តាល និង ១៤ សាខា ។ បណ្តាញប្រតិបត្តិការទូទាំងប្រទេស លើកលែងតែតំបន់ Gyeongnam

- ការិយាល័យកណ្តាល Cheongdam [ធនាគារសន្សំប្រាក់ ហ៊ីយ៉ាន់ដាយ ស្វីស]
  78-6 Cheongdam-Dong, Gangnam-Gu, Seoul
- សាខាស្ថានីយ៍ Gangnam [ធនាគារសន្សំប្រាក់ ហ៊ីយ៉ាន់ដាយ ស្វីស]
  Gyeongwon B/D 2F, 831-17 Yeoksam-Dong, Gangnam-Gu, Seoul
- សាខា Olympic [ធនាគារសន្សំប្រាក់ ហ៊ីយ៉ាន់ដាយ ស្វីស]
  Geumbok B/D 1F, 45-2 Bang-i-Dong, Songpa-Gu, Seoul
- សាខាស្ថានីយ៍ Myeongdong [ធនាគារសន្សំប្រាក់ ហ៊ីយ៉ាន់ដាយ ស្វីស]
  Cygnus B/D 1F, Namsan-Dong 2-ga, Chung-Gu, Seoul
- សាខាស្ថានីយ៍ Yongsan [ធនាគារសន្សំប្រាក់ ហ៊ីយ៉ាន់ដាយ ស្វីស]
  Handeok B/D 1F, Hangangno 3-ga, Yongsan-Gu, Seoul
- សាខាស្ថានីយ៍ Mokdong [ធនាគារសន្សំប្រាក់ ហ៊ីយ៉ាន់ដាយ ស្វីស]
  205-201 Hyperion 2nd, Mok-Dong, Yangcheon-Gu, Seoul
- ការិយាល័យកណ្តាល Bundang [ធនាគារសន្សំប្រាក់ ហ៊ីយ៉ាន់ដាយ ស្វីស៤]
  Hooners B/D 1F, 22-2 Sunae-Dong, Bundang-Gu, Gyeonggi
- សាខា Jeonju [ធនាគារសន្សំប្រាក់ ហ៊ីយ៉ាន់ដាយ ស្វីស៤]
  Daeshin Securities B/D 1F, Seonosong-Dong, Jeonju, Jeonbuk



- ការិយាល័យកណ្តាល Samsung [ធនាគារសន្សំប្រាក់ ហ៊ីយ៉ាន់ដាយ ស្វីស២]
  Hyundai Swiss Tower, Samseong-Dong, Gangnam-Gu, Seoul
- សាខាស្ថានីយ Isu [ធនាគារសន្សំប្រាក់ ហ៊ីយ៉ាន់ដាយ ស្វីស២]
  Dongju B/D 1F, Bangbae-Dong, Seocho-Gu, Seoul
- សាខាស្ថានីយ៍ Nowon [ធនាគារសន្សំប្រាក់ ហ៊ីយ៉ាន់ដាយ ស្វីស២]
  Hyundai B/D 3F, 737 Sanggye-Dong, Nowon-Gu, Seoul
- សាខា Miasamgeori [ធនាគារសន្សំប្រាក់ ហ៊ីយ៉ាន់ដាយ ស្វីស២]
  2F 864-18 Gileum-Dong, Seongbuk-Gu, Seoul
- ការិយាល័យកណ្តាល Jincheon [ធនាគារសន្សំប្រាក់ ហ៊ីយ៉ាន់ដាយ ស្វីស៣]
  67 Eupnae-Ri, Jincheon-Eup, Jincheon-Gun, Chungbuk
- សាខា Daegu [ធនាគារសន្សំប្រាក់ ហ៊ីយ៉ាន់ដាយ ស្វីស៤]
  2F Banwol B/D, Samdeok-Dong, Chung-Gu, Daegu
- សាខា Pohang [ធនាគារសន្សំប្រាក់ ហ៊ីយ៉ាន់ដាយ ស្វីស៤]
  49-23 Jukdo-Dong, Buk-Gu, Pohang, Gyeongbuk
- សាខា Bundang [ធនាគារសន្សំប្រាក់ ហ៊ីយ៉ាន់ដាយ ស្វីស៣]
  Jeongja station plaza 2F, Jeongja-Dong, Bundang-Gu, Seongnam, Gyeonggi
- សាខា Ilsan [ធនាគារសន្សំប្រាក់ ហ៊ីយ៉ាន់ដាយ ស្វីស៣]
  Daehan Life B/D 3F, Dong-Gu, Ilsan, Goyang, Gyeonggi
- សាខាស្ថានីយ៍ Daechi [ធនាគារសន្សំប្រាក់ ហ៊ីយ៉ាន់ដាយ ស្វីស៣]
  One Plus arcade 3F, 507 Daechi-Dong, Gangnam-Gu, Seoul

# HSFG Building



# Izumi Garden Tower



# សេចក្ដីផ្ដើមរបស់ SBI Holdings

ការវិវឌ្ឍនៃប្រព័ន្ធអ៊ីនធឺណែតត្រូវបានបង្កើតឡើងដោយ Big Bang ហិរញ្ញវត្ថុ ដែលទទួលបានពីការបន្ធូរបន្ថយនៃបទបញ្ញត្តិនិងគំនិតច្នៃប្រឌិតបច្ចេកវិទ្យាព័ត៌មានដ៏ឆាប់រហ័ស (បច្ចេកវិទ្យាព័ត៌មាន)។SBI Holdings គឺជាសាជីវកម្មហិរញ្ញវត្ថុ ដែលមានបំណងផ្តល់សេវាកម្មទាំងអស់នៅកន្លែងតែមួយ ជាតុមួយ និងពីម្នាក់ទៅម្នាក់ ដែលរួមបញ្ចូលរាល់សេវាកម្មហិរញ្ញវត្ថុទាំងអស់ តាមរយៈប្រព័ន្ធអ៊ីនធឺណែត។

## ព័ត៌មាន

| | | |
|---|---|---|
| កាលបរិច្ឆេទបង្កើត | : | ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ១៩៩៩ |
| ដើមទុន | : | ៥៥.២១៤ លានយ៉េន |
| ចំនួននិយោជិត | : | ២.៤៩២នាក់ (បូកសរុបទាំងអស់) |
| នាយកប្រតិបត្តិ | : | យូស៊ីតាកា គីតាវ |
| អាសយដ្ឋាន | : | អ៊ីហ្សូមី ហ្គាដិន ថោវើ ជាន់ទី១៩, ១-៦-១ រ៉ូប៉ុងហ្គិ, មីណាតុ-គុ, ទីក្រុងតូក្យូ ១០៦-៦០១៩ ប្រទេសជប៉ុន |

## ទស្សនៈវិស័យ

### តម្លៃសីលធម៌ត្រឹមត្រូវ

យើងនឹងធ្វើការវិនិច្ឆ័យលើសកម្មភាពនានាមិនត្រឹមតែថាតើសកម្មភាព ទាំងនោះស្របតាម ច្បាប់រឺផ្ដល់ប្រយោជន៍ដល់ក្រុមហ៊ុនដែររឺយ៉ាងណានោះទេប៉ុន្តែថែមទាំងថាតើសកម្មភាពនោះមានសមធម៌សង្គមដែររឺ យ៉ាងណា?

### អ្នកច្នៃប្រឌិតហិរញ្ញវត្ថុ

យើងនឹងពុះពារលើវិធីសាស្ត្រតាមបែបប្រពៃណី និង នាំមកនូវការច្នៃប្រឌិតហិរញ្ញវត្ថុ ឱ្យមានភាពលេចធ្លោនៃឧស្សាហកម្មហិរញ្ញវត្ថុដោយប្រើប្រាស់ឱកាស ដែលទទួលបានពីការស្រុតចុះ នៃតំលៃដ៏មានឥទ្ធិពលនៃប្រព័ន្ធអ៊ីនធឺណែត និង បង្កើតសេវាកម្មហិរញ្ញវត្ថុដែលបង្កើនអត្ថប្រយោជន៍ថែម ទៀតសំរាប់អតិថិជន។




### ស្ថាបនិកឧស្សាហកម្មថ្មី

យើងនឹងធ្វើការដើម្បីឱ្យក្លាយជាមេដឹកនាំក្នុងការបង្កើត និងសាបព្រោះឧស្សាហកម្មស្នូលនៅសតវត្សរ៍ទី២១។

### ស្វ័យវិវឌ្ឍន៏កម្ម

យើងនឹងបន្តធ្វើជាក្រុមហ៊ុនមួយដែលវិវឌ្ឍន៏នូវឆន្ទៈផ្ទាល់របស់ខ្លួនតាមរយៈការបង្កើត ក្រុមហ៊ុនដែលសម្រប ទៅតាមការផ្លាស់ប្តូរនៅក្នុងបរិយាកាសប្រតិបត្តិការ និង ដាក់បញ្ចូលនូវ "ភាពប៉ិនប្រសព្វ" រួមនឹង "ការផ្លាស់ប្តូរដោយខ្លួនឯង" ជាផ្នែកមួយនៃ DNA របស់ក្រុមហ៊ុនរបស់ខ្លួន។

### ទំនួលខុសត្រូវសង្គម

យើងនឹងធានាថា ក្រុមហ៊ុននីមួយៗនៅ SBIH Group ទទួលស្គាល់នូវការទទួលខុសត្រូវសង្គមរបស់ខ្លួនក្នុងនាម ជាសមាជិកសង្គមខណៈពេលដែលកំពុងបំពេញតម្រូវការនៃ តួអង្គពាក់ព័ន្ធរបស់ខ្លួន ដោយរួមចំណែកក្នុងការលើកស្ទួយសង្គម។

### ទស្សនៈវិស័យនៃ SBIH Group (បង្កើតឡើងនៅខែមេសា ឆ្នាំ២០០៨)

១. បង្កើនប្រាក់ចំណូលប្រតិបត្តិការដល់ទៅ ១០០ពាន់លានយេន ក្នុងរយៈពេល៥ឆ្នាំ (ឆ្នាំបញ្ចប់នៅ ខែមីនា ឆ្នាំ២០១៣)

២. ពង្រីកការគ្រប់គ្រងអចលនទ្រព្យ និងជំនួញឈ្មួញកណ្ដាលនិងវិនិយោគធនាគារដល់ទៅ២/៣ នៃចំណូលប្រតិបត្តិការនៅត្រឹមខែមីនា ឆ្នាំ២០១៣ ជាមួយអាជីវកម្មទាំងអស់ផ្សេងទៀតមានចំនួន១/៣ដែលនៅសល់

៣. ផ្លាស់ប្តូរ SBIH Group ឱ្យទៅជាអង្គភាពពិភពលោកដែលរកប្រាក់ចំណូលប្រតិបត្តិបានពាក់កណ្ដាលនៅក្រៅប្រទេសជប៉ុន នៅឆ្នាំបញ្ចប់នៅត្រឹមខែមីនា ឆ្នាំ២០១៣។

# យុទ្ធសាស្ត្រអាជីវកម្មរបស់ SBI Holdings

## ព័ត៌មានសង្ខេបរបស់ SBIH

| | អនុបាតចំណូលប្រតិបត្តិការ ធៀបជាមួយនឹងការបញ្ចូលគ្នានូវចំណូលប្រតិបត្តិការ (២០០៨ នឹង ២០០៩) | ចំណូលប្រតិបត្តិការ (ពាន់លានយ៉េន) |
|---|---|---|
| អាជីវកម្មគ្រប់គ្រងទ្រព្យសកម្ម |  |  |
| ការវិនិយោគលើវិស័យធនាគារ និងឈ្មួញកណ្ដាល |  |  |
| អាជីវកម្មសេវាកម្មហិរញ្ញវត្ថុ |  |  |
| អាជីវកម្មលើវិស័យអចលនទ្រព្យ និងលំនៅដ្ឋាន |  |  |
| អាជីវកម្មលើដំណោះស្រាយប្រព័ន្ធ |  |  |

## ចំណូលប្រតិបត្តិការ( ខាត)
( ពាន់លានយ៉េន )

## ចំណូលប្រតិបត្តិការតាមប្រភេទអាជីវកម្ម
( ភាគហ៊ុននៃចំណូលរួមបញ្ចូលគ្នានៅក្នុងឆ្នាំដែលបញ្ចប់ក្នុងខែមីនា ឆ្នាំ២០០៩និង ២០១០ )






























# ធនាគារភ្នំពេញពាណិជ្ជ សន្យានាំមកនូវអនាគតដ៏ត្រចះត្រចង់ដល់ប្រទេសកម្ពុជា

ប្រជាជនកម្ពុជាអាចសំលឹងទៅរកអនាគតដ៏ត្រចះត្រចង់ និង ទទួលយកនូវមោទនភាពដែលជាប្រជាជនដើមនៃអាណាចក្រអង្គរ ។ ធនាគារ ភ្នំពេញពាណិជ្ជ បានរៀបចំខ្លួនជាមួយចំណេះដឹងហិរញ្ញវត្ថុដែលមានលក្ខណៈវិជ្ជាជីវៈ និង ប្រព័ន្ធវិទ្យាសាស្រ្ត ក្នុងការពង្រីកទ្រព្យសកម្មដែលមានតំលៃរបស់អតិថិជនគ្រប់គ្នា ដើម្បីលើកតំកើងប្រសិទ្ធភាពអោយខ្ពស់បំផុត ។

ទ្រព្យសកម្មដែលអតិថិជនប្រគល់ មកអោយ ធនាគារ ភ្នំពេញ ពាណិជ្ជ ជាមូលដ្ឋាននៃការរីកចំរើនរបស់ប្រទេសកម្ពុជា ហើយយើង នឹងប្រើប្រាស់រាល់លទ្ធភាពដែលមាន ដើម្បីទទួបានលទ្ធផលជាផ្លែផ្កា ពីមូលដ្ឋានដ៏មានតំលៃនេះ ។
យើងនឹងផ្តល់ជូនអតិថិជនរបស់យើងជាមួយសេវាកម្មហិរញ្ញវត្ថុ ដែលប្លែកពីគេ និងមិនធ្លាប់មានពីមុន ដែលជាផ្នែកមួយនៃការសន្យារបស់យើង ដើម្បីបន្តការអភិវឌ្ឍតំលៃនិមិត្តសញ្ញារបស់ប្រទេសកម្ពុជា ។



ធនាគារ ភ្នំពេញ ពាណិជ្ជ

Phnom Penh Commercial Bank

# របាយការណ៍ហិរញ្ញវត្ថុ

## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល ធនាគារ ភ្នំពេញ ពាណិជ្ជ ហៅកាត់ថា ("ធនាគារ") មានកិត្តិយស សូមដាក់ជូនពិនិត្យនូវ របាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្មរួច សំរាប់ការិយបរិច្ឆេទ បញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010 ។

## សកម្មភាពចំបង

សកម្មភាពចំបងរបស់ធនាគារ រួមមានការធ្វើប្រតិបត្តិការលើរាល់សកម្មភាពអាជីវកម្មធនាគារ និងការផ្តល់នូវ សេវាកម្មហិរញ្ញវត្ថុ ដែលពាក់ព័ន្ធផ្សេងៗទៀត ។

ពុំមានការផ្លាស់ប្តូរជាសារវ័ន្តលើសកម្មភាពចំបងរបស់ធនាគារនៅក្នុងកំឡុងពេលហិរញ្ញវត្ថុនេះទេ ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារសំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010 មានដូច ខាងក្រោមៈ

| | ដុល្លារអាមេរិក |
|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | 728,174 |
| ពន្ធលើប្រាក់ចំណេញ | (133,994) |
| ប្រាក់ចំណេញសុទ្ធសំរាប់ការិយបរិច្ឆេទ | 594,180 |

## ភាគលាភ

ពុំមានការប្រកាស ឬការបែងចែកភាគលាភទេ ហើយក្រុមប្រឹក្សាភិបាលមិនបានស្នើឱ្យមានការបែងចែក ភាគលាភ សំរាប់ការិយបរិច្ឆេទ ដែលត្រូវត្រួតពិនិត្យនេះទេ ។

## ដើមទុន

ពុំមានការផ្លាស់ប្តូរនូវភាគហ៊ុនរបស់ធនាគារដែលបានចុះបញ្ជី និងបានបែងចែក សំរាប់ការិយបរិច្ឆេទ ដែលត្រូវត្រួតពិនិត្យនេះទេ ។

នៅថ្ងៃទី 7 ខែ កក្កដា ឆ្នាំ 2010 ធនាគារជាតិនៃកម្ពុជា បានចេញសារាចរលេខ ធ7-010-001 ស្តីពីការ កំណត់ជាថ្មីនូវដើមទុនចុះបញ្ជី និងលក្ខខណ្ឌសុំអាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានធនាគារ ដែលតំរូវអោយ ធនាគារពាណិជ្ជ ដែលមិនមានភាគទុនិកមានឥទ្ធិពលយ៉ាងតិចមួយជាគ្រឹះស្ថានធនាគារ ឬជាគ្រឹះស្ថាន ហិរញ្ញវត្ថុដែលមានការវាយតំលៃ "ចំណាត់ថ្នាក់វិនិយោគ" ដោយភ្នាក់ងារចាត់ថ្នាក់ឯករាជ្យអន្តរជាតិ យ៉ាងតិចមួយ រួមមាន Moody's Asia Pacific, Standard & Poor's corporation និង Fitch ត្រូវមាន ដើមទុនអប្បបរមាស្មើនឹង 150 ពាន់លានរៀល ។

នៅថ្ងៃទី 3 ខែ កញ្ញា ឆ្នាំ 2010 ធនាគារជាតិនៃកម្ពុជា បានអនុម័តឱ្យធនាគារ រួចផុតពីផែនការ បង្កើនដើមទុនបន្ថែម រហូតដល់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011។

នៅថ្ងៃទី16ខែវិច្ឆិកាឆ្នាំ2010ភាគទុនិកទាំងអស់របស់ធនាគារបានសំរេចយល់ព្រមទៅលើការបង្កើនដើមទុនបន្ថែម។ ធនាគារ នឹងបន្ថែមដើមទុនចំនួន 6,000,000 ដុល្លារអាមេរិក នៅថ្ងៃទី 30 ខែ មិថុនា និងចំនួន 18,000,000 ដុល្លារអាមេរិក នៅថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2011 ។

## ទុនបំរុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវ័ន្តទៅលើទុនបំរុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការ បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## ឥណទាន និងបុរេប្រទានអាក្រក់ និងជាប់សង្ស័យ

នៅមុនពេលរៀបចំ តារាងតុល្យការ និងរបាយការណ៍លទ្ធផលរបស់ធនាគារ គណៈនាយកបាន ប្រកាន់យកជំហានសមស្របដើម្បីធានាថា វិធានការទាក់ទងទៅនឹងការលុបបំបាត់ចោលឥណទាន និង បុរេប្រទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទាន និងបុរេប្រទានជាប់សង្ស័យត្រូវបានធ្វើឡើង ។ គណៈនាយកមានការជឿជាក់ថា រាល់ឥណទាន និងបុរេប្រទាន ដែលទទួលស្គាល់ថាមិនអាចទារបាន ត្រូវបានលុបបំបាត់ចោល ហើយសំវិធានធនពេញលេញ ត្រូវបានកំណត់ឡើងសំរាប់ឥណទាន និង បុរេប្រទាន ដែលជាប់សង្ស័យ ។

នាថ្ងៃចេញរបាយការណ៍នេះគណៈនាយកពុំបានពិនិត្យឃើញមានស្ថានភាពណាមួយដែលអាចនឹងបណ្តាលឱ្យចំនួននៃការលុបបំបាត់ចោលឥណទាន និងបុរេប្រទានអាក្រក់ ឬចំនួននៃការធ្វើសំវិធានធន លើឥណទាន និងបុរេប្រទានជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ មានចំនួនខ្វះខាតជា សារវ័ន្តនោះឡើយ ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលរៀបចំ តារាងតុល្យការ និងរបាយការណ៍លទ្ធផលរបស់ធនាគារ គណៈនាយកបាន ប្រកាន់យកជំហានសមស្របដើម្បីធានាថា តម្លៃទ្រព្យសកម្មចរន្តទាំងអស់លើកលែងបំណុលដែលបាន កត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ធនាគារ ហើយដែលសន្និដ្ឋានថាមិនអាចលក់បាននៅក្នុងប្រតិបត្តិ ការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឱ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចប្រមូលបានជាក់ស្តែង ។

នាថ្ងៃចេញរបាយការណ៍នេះ គណៈនាយកពុំបានពិនិត្យឃើញមានស្ថានភាពណាមួយដែលនឹងធ្វើឱ្យប៉ះ ពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារថា មានភាពមិន ត្រឹមត្រូវនោះឡើយ ។
នាថ្ងៃចេញរបាយការណ៍នេះ គណៈនាយកពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឲ្យប៉ះពាល់ ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារថា មានភាពមិនត្រឹមត្រូវ នោះទេ ។

## វិធីសាស្ត្រកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ គណៈនាយកពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងដែល ធ្វើឱ្យការប្រកាន់យកវិធីសាស្ត្រដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងទ្រព្យអកម្មនៅក្នុង របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះឡើយ ។

## បំណុលយថាហេតុ និងទ្រព្យអកម្មផ្សេងៗទៀត

នាថ្ងៃចេញរបាយការណ៍នេះ ពុំមានៈ

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ធនាគារ ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមក ដែលធានា ចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះធនាគារ ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទ មកក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារឡើយ។

គណៈនាយកយល់ឃើញថា ពុំមានបំណុលយថាហេតុ ឬទ្រព្យអកម្មផ្សេងៗទៀត ដែលធនាគារត្រូវ បំពេញ ឬអាចនឹងត្រូវបំពេញក្នុងកំឡុងពេលដប់ពីរខែបន្ទាប់ពីថ្ងៃបញ្ចប់ការិយបរិច្ឆេទដែលនឹងមានផល ប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ធនាគារ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដល់ថ្ងៃកំណត់ ឡើយ ។

## ការផ្លាស់ប្តូរនៃហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះគណៈនាយករបស់ធនាគារពុំបានពិនិត្យឃើញសភាពការណ៍ណាមួយដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលអាចនឹងបណ្តាលឱ្យតួលេខនៃចំនួនណាមួយ ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិន ត្រឹមត្រូវនោះទេ ។

## ប្រតិបត្តិការមិនប្រក្រតី

តាមមតិយោបល់របស់គណៈនាយក លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ធនាគារក្នុងការិយបរិច្ឆេទនេះ មិនមានផលប៉ះពាល់ជាសារវ័ន្តណាមួយដល់ចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈជាសារវ័ន្ត និងមិនប្រក្រតីនោះទេ ។

គណៈនាយកក៏យល់ឃើញផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទ រហូតដល់ថ្ងៃចេញ របាយការណ៍នេះពុំមានកត្តាសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយអាចកើតមាន ឡើងធ្វើឱ្យប៉ះពាល់ដល់លទ្ធផលប្រតិបត្តិការរបស់ធនាគារ ក្នុងការិយបរិច្ឆេទ ដែលរបាយការណ៍នេះ បានរៀបចំឡើងនោះទេ ។

## ក្រុមប្រឹក្សាភិបាល

គណៈនាយកដែលបានបម្រើការចាប់តាំងពីកាលបរិច្ឆេទនៃរបាយការណ៍ចុងក្រោយៈ

លោក Kim Yang Jin

លោក Eiichiro So

លោក Ha Hong Sik ( លាលែងនៅថ្ងៃទី 15 ខែកញ្ញា ឆ្នាំ2010 )

## ចំណែកហ៊ុនរបស់គណៈនាយក

ពុំមានគណៈនាយកណាម្នាក់កាន់កាប់ ឬមានការទាក់ទិនផ្ទាល់នៅក្នុងភាគហ៊ុនរបស់ធនាគារ នៅក្នុង ការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ ។

## អត្ថប្រយោជន៍របស់គណៈនាយក

នៅក្នុង និងចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ធនាគារពុំបានចូលរួមក្នុងកិច្ចចាត់ចែងណាមួយក្នុងគោល បំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារឱ្យទទួលបានអត្ថប្រយោជន៍ ដោយការទិញ យកភាគហ៊ុន ឬលិខិតបំណុលពីធនាគារ ឬពីក្រុមហ៊ុនដទៃទេ ។

នៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុ ពុំមានគណៈនាយករបស់ធនាគារណាម្នាក់ បានទទួល ឬមានសិទ្ធិទទួល បាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ ដែលបានរួមបញ្ចូល នៅក្នុងចំនួនបុព្វលាភសរុប ទទួលបាន ឬដល់កំណត់ទទួលបានដោយគណៈនាយក ដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈកិច្ចសន្យាដែលធ្វើឡើងដោយធនាគារ ឬជាមួយក្រុមហ៊ុនពាក់ព័ន្ធដែលគណៈនាយកនោះជា សមាជិក ឬក៏ជាមួយក្រុមហ៊ុន ដែលគណៈនាយកនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែការបង្ហាញនៅលើរបាយការណ៍ហិរញ្ញវត្ថុ ។

## ការទទួលខុសត្រូវរបស់គណៈនាយកលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈនាយកមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវ ដើម្បីចង្អុលបង្ហាញនូវភាពពិតនិងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់នាគារនាថ្ងៃទី31ខែធ្នូឆ្នាំ2010និងនូវលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម បំរែបំរួលមូលនិធិម្ចាស់ហ៊ុន និងស្ថានភាពចលនាសាច់ប្រាក់ សំរាប់ការិយបរិច្ឆេទបញ្ចប់ ។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ គណៈនាយកចាំបាច់ត្រូវៈ

ក) ប្រកាន់យកគោលការណ៍គណនេយ្យសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណ យ៉ាងសម

ហេតុផល និងប្រុងប្រយ័ត្ន ហើយអនុវត្តន៍គោលការណ៍ទាំងនោះឱ្យបានជាប់លាប់ ។

ខ)  គោរពទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំនិងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឬប្រសិនបើមានការផ្លាស់ប្តូរពីនេះដើម្បីបង្ហាញនូវភាពពិត និងត្រឹមត្រូវ គឺត្រូវបង្ហាញ និងពន្យល់ឱ្យបានច្បាស់លាស់ និងកំណត់បរិមាណនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

គ)  រក្សាទុកបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធនៃការគ្រប់គ្រងផ្ទៃក្នុង ឱ្យមានប្រសិទ្ធិភាព ។

ឃ)  រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តភាពនៃដំណើរការអាជីវកម្ម លុះត្រាតែ មានករណីមិនសមរម្យក្នុងការសន្មតថា ធនាគារនឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មនាពេលអនាគត ដែលគិតទុកជាមុន និង

ង)  ត្រួតពិនិត្យ និងដឹកនាំធនាគារឱ្យមានប្រសិទ្ធិភាពលើរាល់សេចក្តីសំរេច សំខាន់ៗទាំងឡាយ ដែលប៉ះពាលដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ធនាគារ ហើយត្រូវប្រាកដថាកិច្ចការនេះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

គណៈនាយកធានាអះអាងថា បានអនុវត្តនូវរាល់តម្រូវការ ដូចមានរាយការណ៍ខាងលើ ក្នុងការរៀបចំ របាយការណ៍ហិរញ្ញវត្ថុ ។

ចុះហត្ថលេខាដោយយោងទៅលើសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលៈ

លោក Kim Yang Jin
អគ្គនាយក/នាយកប្រតិបត្តិ

លោក Eiichiro So
នាយក

លោក Yun Chang Ho
ប្រធានជាន់ខ្ពស់

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១

# របាយការណ៍របស់សវនករឯករាជ្យ

## ជូនចំពោះម្ចាស់ភាគហ៊ុន ធនាគារ ភ្នំពេញពាណិជ្ជ

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារ ភ្នំពេញ ពាណិជ្ជ ហៅកាត់ថា (" ធនាគារ ") ដែលរួមមានតារាងតុល្យការនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010 និងរបាយការណ៍លទ្ធផល របាយការណ៍បំរែបំរួលមូលនិធិម្ចាស់ហ៊ុន និងរបាយការណ៍ចលនាសាច់ប្រាក់ សំរាប់ការិយបរិច្ឆេទ បញ្ចប់ និងសេចក្តីសង្ខេបលើគោល នយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងកំណត់សំគាល់ផ្សេងៗ ដែលបានបង្ហាញនៅទំព័រទី 8 ដល់ទី 50 ។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងរបស់ធនាគារ មានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពពិត និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ ហិរញ្ញវត្ថុ ព្រមទាំងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងដែលគណៈគ្រប់គ្រងបានកំណត់ថា មានភាពចាំបាច់សំរាប់ការ រៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យជៀសផុតពីកំហុសឆ្គងជាសារវ័ន្តបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ ច្រឡំ ។

## ការទទួលខុសត្រូវរបស់សវនករ

ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺបញ្ចេញមតិយោបល់លើរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ផ្អែកទៅលើការធ្វើសវនកម្មរបស់យើងខ្ញុំ ។ យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្ម អន្តរជាតិនៃកម្ពុជា ។ ស្តង់ដារ ទាំងនេះតម្រូវឱ្យយើងខ្ញុំអនុវត្តទៅតាមតម្រូវការក្រមសីលធម៌ ដោយ គ្រោងនិងធ្វើសវនកម្មដើម្បីទទួលបាននូវអំណះអំណាងយ៉ាងសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុពុំ មានកំហុសឆ្គងជាសារវ័ន្តឡើយ ។

ការធ្វើសវនកម្ម រួមមានការអនុវត្តន៍នូវបណ្តានិតិវិធីត្រួតពិនិត្យ ដើម្បីទទួលបាននូវភស្តុតាងដែលទាក់ ទងទៅនឹងបរិមាណទឹកប្រាក់ និងកំណត់បង្ហាញទាំងឡាយនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។ ការជ្រើស រើសនិតិវិធីទាំងនេះ ផ្អែកទៅលើការវិនិច្ឆ័យរបស់យើងខ្ញុំដែលរួមមានការប៉ាន់ប្រមាណទៅលើហានិភ័យ ដែលមានផលប៉ះពាល់ជាសារវ័ន្តលើរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្តាលមកពីការក្លែងបន្លំឬការភាន់ ច្រឡំ។នៅក្នុងការប៉ាន់ប្រមាណហានិភ័យទាំងនោះ យើងខ្ញុំធ្វើការពិចារណាទៅលើការ គ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធទៅនឹងការរៀបចំ និងការបង្ហាញនូវភាពពិតនិងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីធ្វើ សវនកម្មឱ្យសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិយោបល់ ប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ធនាគារឡើយ ។ ការធ្វើសវនកម្ម ក៏រួមមានការវាយតម្លៃទៅលើ ភាពសមស្របនៃគោលនយោបាយគណនេយ្យ ដែលធនាគារបានប្រើប្រាស់ និងភាពសម

ហេតុផលនៃ ការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ដែលធ្វើឡើងដោយគណៈគ្រប់គ្រង ព្រមទាំងការវាយតម្លៃលើភាពគ្រប់គ្រាន់នៃការបង្ហាញនៅក្នុងរបាយកាណ៍ហិរញ្ញវត្ថុ ។

យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប សំរាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។

## មតិយោបល់

ជាមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវភាពពិត និងត្រឹមត្រូវនៃស្ថានភាព ហិរញ្ញវត្ថុរបស់ធនាគារ ភ្នំពេញ ពាណិជ្ជនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010 ព្រមទាំងលទ្ធផលនៃប្រតិបត្តិការ អាជីវកម្ម និងស្ថានភាពចលនាសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ ដោយស្របទៅតាមស្តង់ដារ គណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការ កំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

**តំណាងក្រុមហ៊ុន ខេភីអឹមជី ខេមបូឌា ចំកាត់**

Craig McDonald

Audit Partner

រាជធានីភ្នំពេញ

ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១

## តារាងតុល្យការ
## នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010

| | កំណត់សំគាល់ | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល (កំណត់សំគាល់ទី 4) | 2009 ដុល្លារអាមេរិក |
|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | |
| សាច់ប្រាក់ និងសមតុល្យធនាគារ | 5 | 7,826,158 | 31,719,418 | 3,162,752 |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារនានា | 6 | 21,772,503 | 88,243,955 | 14,649,436 |
| ឥណទាន និងបុរេប្រទានសុទ្ធ | 7 | 24,499,495 | 99,296,453 | 12,660,418 |
| ទ្រព្យសកម្មផ្សេងៗ | 8 | 625,629 | 2,535,675 | 266,758 |
| ប្រាក់បញ្ញើតម្កល់តាមច្បាប់ | 9 | 2,837,000 | 11,498,361 | 2,227,000 |
| ទ្រព្យសកម្មអរូបិយ | 10 | 243,594 | 987,286 | 335,221 |
| អចលនទ្រព្យ និងទ្រព្យសម្ភារៈ | 11 | 546,415 | 2,214,620 | 743,574 |
| **សរុបទ្រព្យសកម្ម** | | 58,350,794 | 236,495,768 | 34,045,159 |
| **ទ្រព្យអកម្ម និងមូលនិធិម្ចាស់ហ៊ុន** | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | 12 | 19,349,496 | 78,423,507 | 4,978,294 |
| ប្រាក់បញ្ញើរបស់ធនាគារ | 13 | 22,758,654 | 92,240,825 | 14,144,912 |
| ទ្រព្យអកម្មផ្សេងៗ | 14 | 704,531 | 2,855,464 | 76,924 |
| សំវិធានធនសំរាប់ពន្ធលើប្រាក់ចំណេញ | 20 | 101,448 | 411,169 | 2,544 |
| សរុបទ្រព្យអកម្ម | | 42,914,129 | 173,930,965 | 19,202,674 |
| **មូលនិធិម្ចាស់ហ៊ុន** | | | | |
| ដើមទុន | 15 | 15,000,000 | 60,795,000 | 15,000,000 |
| ប្រាក់ចំណេញរក្សាទុក/ប្រាក់ខាតបង្គរ | | 436,665 | 1,769,803 | (157,515) |
| សរុបមូលនិធិម្ចាស់ហ៊ុន | | 15,436,665 | 62,564,803 | 14,842,485 |
| **សរុបទ្រព្យអកម្ម និងមូលនិធិម្ចាស់ហ៊ុន** | | 58,350,794 | 236,495,768 | 34,045,159 |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយគឺជាបតិដ្ឋានបទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ

# របាយការណ៍លទ្ធផល
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010

| | កំណត់សំគាល់ | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល (កំណត់សំគាល់ទី 4) | 2009 ដុល្លារអាមេរិក |
|---|---|---|---|---|
| ចំណូលពីការប្រាក់ | 16 | 2,992,801 | 12,129,822 | 1,883,507 |
| ចំណាយលើការប្រាក់ | 17 | (1,074,666) | (4,355,621) | (322,192) |
| ចំណូលការប្រាក់សុទ្ធ | | 1,918,135 | 7,774,201 | 1,561,315 |
| ចំណូលលើកំរៃជើងសារនិងថ្លៃឈ្នួល | 18 | 622,440 | 2,522,749 | 346,333 |
| ចំណាយរដ្ឋបាលទូទៅ | 19 | (1,701,906) | (6,897,825) | (1,442,857) |
| សំវិធានធនសំរាប់ឥណទាន និង បុរេប្រទានអាក្រក់ និងជាប់សង្ស័យ | 7 | (110,495) | (447,836) | (83,556) |
| ប្រាក់ចំណេញមុនបង់ពន្ធ | | 728,174 | 2,951,289 | 381,235 |
| ពន្ធលើប្រាក់ចំណេញ | 20 | (133,994) | (543,078) | (21,816) |
| ប្រាក់ចំណេញសុទ្ធសំរាប់ការិយបរិច្ឆេទ | | 594,180 | 2,408,211 | 359,419 |

# របាយការណ៍បំរែបំរួលមូលនិធិម្ចាស់ហ៊ុន
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010

| | ដើមទុន ដុល្លារអាមេរិក | (ប្រាក់ខាតបង្គរ)/ ប្រាក់ចំណេញរក្សាទុក ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|
| សមតុល្យនាថ្ងៃទី 1 ខែ មករា ឆ្នាំ 2009 | 15,000,000 | (516,934) | 14,483,066 |
| ចំណេញសុទ្ធសំរាប់ការិយបរិច្ឆេទ | - | 359,419 | 359,419 |
| សមតុល្យនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2009 | 15,000,000 | (157,515) | 14,842,485 |
| ចំណេញសុទ្ធសំរាប់ការិយបរិច្ឆេទ | | 594,180 | 594,180 |
| សមតុល្យនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010 | 15,000,000 | 436,665 | 15,436,665 |
| (ស្មើនឹងពាន់រៀល - កំណត់សំគាល់ទី 4) | 60,795,000 | 1,769,803 | 62,564,803 |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយគឺជាបតិដ្ឋានបទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ

# របាយការណ៍ចលនាសាច់ប្រាក់
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010

| | កំណត់សំគាល់ | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល (កំណត់សំគាល់ទី 4) | 2009 ដុល្លារអាមេរិក |
|---|---|---|---|---|
| **ចលនាសាច់ប្រាក់ពីសកម្មភាព ប្រតិបត្តិការ** | | | | |
| សាច់ប្រាក់សុទ្ធពីសកម្មភាព ប្រតិបត្តិការ | 21 | 2,407,121 | 9,756,061 | 8,591,170 |
| **ចលនាសាច់ប្រាក់ពីសកម្មភាព វិនិយោគ** | | | | |
| ការទិញអចលនទ្រព្យ និងទ្រព្យសម្ភារៈ | | (112,883) | (457,515) | (202,167) |
| ការទិញទ្រព្យសកម្មអរូបិយ | | (7,765) | (31,471) | (750) |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង សកម្មភាពវិនិយោគ | | (120,648) | (488,986) | (202,917) |
| **ការកើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | 2,286,473 | 9,267,075 | 8,388,253 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមការិយបរិច្ឆេទ** | | 15,312,188 | 62,060,298 | 6,923,935 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងការិយបរិច្ឆេទ** | 22 | 17,598,661 | 71,327,373 | 15,312,188 |

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010

## 1. រចនាសម្ព័ន្ធ និងសកម្មភាពចំបង

ធនាគារ ភ្នំពេញ ពាណិជ្ជ ហៅកាត់ថា ("ធនាគារ") បានបង្កើតឡើងនៅ ព្រះរាជាណាចក្រកម្ពុជា ជាក្រុមហ៊ុនសាធារណៈទទួលខុសត្រូវមានកំរិត នៅថ្ងៃទី 4 ខែ មិថុនា ឆ្នាំ 2008 ក្រោមការចុះបញ្ជីពាណិជ្ជកម្មលេខ Co-4898/08E និងទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើប្រតិបត្តិការអាជីវកម្មជាធនាគារពាណិជ្ជ ចាប់ពីថ្ងៃទី 27 ខែ សីហា ឆ្នាំ 2008 ។ ធនាគារបានចាប់ផ្តើមប្រតិបត្តិការជាផ្លូវការនៅថ្ងៃទី 1 ខែ កញ្ញា ឆ្នាំ 2008 ។

សកម្មភាពចំបងរបស់ធនាគារ រួមមានការធ្វើប្រតិបត្តិការលើរាល់សកម្មភាពអាជីវកម្ម ធនាគារ និងការផ្តល់នូវសេវាកម្មហិរញ្ញវត្ថុដែលពាក់ព័ន្ធផ្សេងៗទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010 ធនាគារមានសាខាចំនួន 2 នៅក្នុងរាជធានីភ្នំពេញ ។

## 2. មូលដ្ឋាននៃការរៀបចំ

### (ក) របាយការណ៍នៃការអនុវត្តន៍តាម

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងស្របតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានអនុញ្ញាតិ និងសំរេចអនុម័តឱ្យប្រើប្រាស់ដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១ ។

### (ខ) គោលការណ៍នៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើងទៅតាមមូលដ្ឋានតម្លៃដើម ។

### (គ) រូបិយប័ណ្ណសំរាប់ការវាស់វែង និងការកំណត់បង្ហាញ

រូបិយប័ណ្ណជាតិនៃព្រះរាជាណាចក្រកម្ពុជាគឺប្រាក់រៀល ។ ដោយសារធនាគារធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួនផ្អែកលើមូលដ្ឋានប្រាក់ដុល្លារអាមេរិក គណៈគ្រប់គ្រងបានកំណត់ប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណសំរាប់វាស់វែង និងសំរាប់កំណត់បង្ហាញ ព្រោះវាឆ្លុះបញ្ចាំងពីសារធាតុសេដ្ឋកិច្ចនៃប្រភពព្រឹត្តិការណ៍និងកាលៈទេសៈរបស់ធនាគារ ។

### (គ) រូបិយប័ណ្ណសំរាប់ការវាស់វែង និងការកំណត់បង្ហាញ (ត)

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗទៀតក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើប្រាស់អត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ ។ ទ្រព្យសកម្ម និងទ្រព្យអកម្មដែលជារូបិយប័ណ្ណផ្សេងទៀតក្រៅពីដុល្លារអាមេរិក នាថ្ងៃតារាងតុល្យការ ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើប្រាស់អត្រានាថ្ងៃតារាងតុល្យការ ។ ភាពលំអៀងពីការប្តូររូបិយប័ណ្ណដែលកើតមកពីការប្តូរនោះ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល ។

### (ឃ) ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ តំរូវឱ្យគណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យប៉ាន់ស្មាន និងសន្មតផលដែលប៉ះពាល់ដល់ការអនុវត្តន៍នូវគោលការណ៍គណនេយ្យ និងចំនួននៃទ្រព្យសកម្ម ទ្រព្យអកម្ម ចំណូល និងចំណាយដែលបានរាយការណ៍ ។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនោះ ។

ការប៉ាន់ស្មាន និងការសន្មត ត្រូវបានត្រួតពិនិត្យជាប្រចាំ ។ ការកែប្រែទៅលើគណនេយ្យប៉ាន់ស្មាន ត្រូវបានទទួលស្គាល់ និងកត់ត្រានៅក្នុងការិយបរិច្ឆេទដែលការប៉ាន់ស្មាននោះត្រូវបានត្រួតពិនិត្យឡើងវិញ និងនៅក្នុងកំឡុងការិយបរិច្ឆេទ ដែលផលប៉ះពាល់នោះនឹងកើតមានឡើងនាពេលអនាគត ។

ការប៉ាន់ស្មាន និងការវិនិច្ឆ័យគណនេយ្យចំបង ត្រូវបានអនុវត្តនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ រួមមាន ការប៉ាន់ស្មាននូវចំនួនដែលអាចប្រមូលបានមកវិញពីឥណទាន និងបុរេប្រទានដែលបានបង្ហាញនៅក្នុងគោលនយោបាយគណនេយ្យដោយឡែកក្នុងកំណត់សំគាល់ទី 3(ង) ។

## 3. គោលការណ៍គណនេយ្យសំខាន់ៗ

គោលការណ៍គណនេយ្យសំខាន់ៗដែលបានប្រើប្រាស់ដោយធនាគារក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ មានដូចខាងក្រោមៈ

### (ក) ឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្ម និងទ្រព្យអកម្មហិរញ្ញវត្ថុរបស់ធនាគារ រួមមានសាច់ប្រាក់ និងសាច់ប្រាក់សមមូល ការផ្តល់ឥណទាន ទ្រព្យសកម្មផ្សេងៗ ប្រាក់បញ្ញើ និងទ្រព្យអកម្មផ្សេងៗ ។ គោលការណ៍គណនេយ្យលើការទទួលស្គាល់ និងការវាយតម្លៃនូវសមាសធាតុទាំងនេះ ត្រូវបានបង្ហាញនៅក្នុងគោលការណ៍គណនេយ្យដោយឡែកពីគ្នា ។

## (ខ) ព័ត៌មានវិយោគកម្ម

ធនាគារធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួន តែលើសកម្មភាពជាធនាគារពាណិជ្ជ និងស្ថិតនៅក្នុងដែនភូមិសាស្ត្រតែមួយ គឺព្រះរាជាណាចក្រកម្ពុជា ។

## (គ) សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ និងសមតុល្យធនាគារ ប្រាក់បញ្ញើគ្មានកាលកំណត់ និងការវិនិយោគរយៈពេលខ្លីដែលអាចប្តូរជាសាច់ប្រាក់បានក្នុងរយៈពេល 3 ខែ ឬតិចជាងនេះចាប់ពីពេលបានទិញ ហើយដែលអាចប្តូរជាសាច់ប្រាក់បានដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ ។

## (ឃ) ឥណទាន និងបុរេប្រទាន

ឥណទាន និងបុរេប្រទានផ្តល់ឱ្យអតិថិជន ត្រូវបានកត់ត្រានៅក្នុងតារាងតុល្យការ តាមប្រាក់ដើមដកចេញនូវចំនួនទាំងឡាយណាដែលបានលុបចោល និងសំវិធានធន សំរាប់ឥណទាន និងបុរេប្រទានអាក្រក់ និងជាប់សង្ស័យ ។

## (ង) សំវិធានធនសំរាប់ឥណទាន និងបុរេប្រទានអាក្រក់ និងជាប់សង្ស័យ

ដើម្បីអនុវត្តទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា រាល់ឥណទាន និងបុរេប្រទាន ត្រូវបានចាត់ចំណាត់ថ្នាក់ ដោយយោងទៅតាមសមត្ថភាពនៃការទូទាត់សងរបស់ដៃគូពាណិជ្ជកម្ម ។ សមត្ថភាពនៃការទូទាត់សងនេះ ត្រូវបានវាយតម្លៃដោយផ្អែកទៅតាមបទពិសោធន៍នៃការទូទាត់សងពីមុន ល័ក្ខខ័ណ្ឌហិរញ្ញវត្ថុរបស់កូនបំណុលអាជីវកម្ម និងលំហូរសាច់ប្រាក់នាពេលអនាគត លទ្ធភាព និងការស្ម័គ្រចិត្តសងរបស់កូនបំណុល បរិយាកាសហិរញ្ញវត្ថុ និងគុណភាពនៃឯកសារដែលប្រមូលបាន ។

បន្ថែមលើគុណភាពនៃព័ត៌មានខាងលើ ចំនួនថ្ងៃហួសកាលកំណត់សង ត្រូវបានយកមកគិតដូចខាងក្រោម:

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃហួសកាលកំណត់សង |
|---|---|
| បំណុលធម្មតា/ស្តង់ដារ | <30 ថ្ងៃ |
| បំណុលឃ្លាំមើល | > 30 ថ្ងៃ – 90 ថ្ងៃ |
| បំណុលក្រោមស្តង់ដារ | > 90 ថ្ងៃ – 180 ថ្ងៃ |
| បំណុលជាប់សង្ស័យ | > 180 ថ្ងៃ – 360 ថ្ងៃ |
| បំណុលបាត់បង់ | លើសពី 360 ថ្ងៃ |

14

## (ង) សំវិធានធនសំរាប់ឥណទាន និងបុរេប្រទានអាក្រក់ និងជាប់សង្ស័យ (ត)

សំវិធានធនសំរាប់ឥណទាន និងបុរេប្រទានជាប់សង្ស័យអប្បបរមា ត្រូវបានកំណត់ដោយផ្អែកទៅតាមចំណាត់ថ្នាក់ដែលបានចាត់ថ្នាក់ ។ នៅពេលមានព័ត៌មានដែលអាចទុកចិត្តបានថា បំណុលបាត់បង់កើតមានឡើងច្រើនជាងតំរូវការអប្បបរមានោះ សំវិធានធនបន្ថែមនឹងត្រូវបានគេធ្វើឡើង ។

| **ចំណាត់ថ្នាក់** | **សំវិធនាធនអប្បបរមា** |
|---|---|
| បំណុលធម្មតា/ស្តង់ដារ | 1% |
| បំណុលឃ្លាំមើល | 3% |
| បំណុលក្រោមស្តង់ដារ | 20% |
| បំណុលជាប់សង្ស័យ | 50% |
| បំណុលបាត់បង់ | 100% |

សំវិធានធនខាងលើត្រូវបានធ្វើឡើងដោយមិនគិតពីតម្លៃនៃទ្រព្យបញ្ចាំទេ លើកលែងតែ ទ្រព្យបញ្ចាំនោះជាសាច់ប្រាក់ដែលបានតម្កល់នៅធនាគារ ហើយក្នុងករណីដែលឥណទាន និងបុរេប្រទានចាត់ថ្នាក់ជាឥណទានបាត់បង់នោះទ្រព្យបញ្ចាំនឹងអាចត្រូវបានពិចារណា ប៉ុន្តែតម្លៃទីផ្សារដែលប៉ាន់ស្មានលើទ្រព្យបញ្ចាំនោះ ត្រូវមានការអនុម័តយល់ព្រមពីធនាគារជាតិនៃកម្ពុជា ដោយផ្អែកតាមករណីនិមួយៗដោយឡែកពីគ្នា ។

សំវិធានធនចំពោះឥណទានដែលបានលុបបំបាត់ចោលពីមុន និងការបញ្ចូលមកវិញនូវសំវិធានធនពីមុន ត្រូវបានបង្ហាញដាច់ដោយឡែករួមជាមួយនឹងសំវិធានធនសុទ្ធរបស់បំណុលអាក្រក់ និងជាប់សង្ស័យក្នុងរបាយការណ៍លទ្ធផល ។

ឥណទានដែលមិនអាចទារបាន ឬចំណែកនៃឥណទានដែលបានចាត់ថ្នាក់ជាឥណទានអាក្រក់ត្រូវបានកាត់ចេញបន្ទាប់ពីមានការគិតគូរទៅលើតម្លៃលក់បាននៃទ្រព្យបញ្ចាំ ហើយប្រសិនបើនៅពេលដែលអ្នកគ្រប់គ្រងវិនិច្ឆ័យឃើញថា ពុំមានសង្ឃឹមនឹងទារបាននូវឥណទានទាំងនោះមកវិញទេ ។

## (ច) ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា ត្រូវបានកត់ត្រាតាមតម្លៃដើម ។

## (ឆ) ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មផ្សេងៗ ត្រូវបានកត់ត្រាទៅតាមតម្លៃដែលបានរំពឹងថានឹងទទួលបាន ។

## (ជ) ប្រាក់បញ្ញើតម្កល់តាមច្បាប់

ប្រាក់បញ្ញើតាមច្បាប់ ត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជា ស្របតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានកំណត់ជាភាគរយនៃដើមទុនអប្បបរមារបស់ធនាគារ និង ប្រាក់បញ្ញើរបស់អតិថិជនដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា ។

## (ឈ) ទ្រព្យសកម្មអរូបិយ

ទ្រព្យសកម្មអរូបិយ រួមមានសូហ្វវែរកុំព្យូទ័រ (Moneta) និង SWIFT សូហ្វវែរ ត្រូវបាន កត់ត្រាតាមតម្លៃដើមដករំលោះបង្គរ និងឱនភាពនៃតម្លៃប្រសិនបើមាន ។

រំលស់លើទ្រព្យសកម្មអរូបិយ ត្រូវបានបញ្ចូលជាចំណាយនៅក្នុងរបាយការណ៍លទ្ធផល ដោយផ្អែកលើមូលដ្ឋាន រំលស់ថេរតាមអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មអរូបិយនិមួយៗ ដែលមានអត្រារំលោះប្រចាំឆ្នាំ ដូចខាងក្រោម:

| | |
|---|---|
| សូហ្វវែរកុំព្យូទ័រ (Moneta) | 20% |
| SWIFT សូហ្វវែរ | 50% |

## (ញ) អចលនទ្រព្យ និងទ្រព្យសម្ភារៈ

(i) អចលនទ្រព្យ និងទ្រព្យសម្ភារៈត្រូវបានកត់ត្រាតាមតម្លៃដើមដករំលោះបង្គរ និងការខាតបង់នៃឱនភាពតម្លៃបង្គរប្រសិនបើមាន ។ នៅពេលដែលធាតុនៃទ្រព្យសម្បត្តិ រួមបញ្ចូលនូវសមាសធាតុសំខាន់ៗ ដែលមានអាយុកាលកំណត់ប្រើប្រាស់ខុសៗគ្នា អចលនទ្រព្យទាំងនោះត្រូវបានចាត់ទុកជាធាតុផ្សេងគ្នានៃអចលនទ្រព្យ និងទ្រព្យសម្ភារៈ ។

(ii) រំលស់លើអចលនទ្រព្យ និងទ្រព្យសម្ភារៈ ត្រូវបានបញ្ចូលជាចំណាយនៅក្នុងរបាយការណ៍លទ្ធផល ដោយផ្អែកលើមូលដ្ឋានរំលស់ថេរ ដោយគិតទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មាននៃពេលវេលាប្រើប្រាស់របស់អចលនទ្រព្យនិមួយៗដែលមានអត្រារំលស់ប្រចាំឆ្នាំដូចខាងក្រោម:

| | |
|---|---|
| ការជួសជុលកែលំអរ | 20% |
| គ្រឿងសង្ហារឹម គ្រឿងបំពាក់ | 25% |
| កុំព្យូទ័រ | 50% |
| យានយន្ត | 25% |

## (ញ) អចលនទ្រព្យ និងទ្រព្យសម្ភារៈ (ត)

(iii) ការចំណាយបន្ទាប់ដែលពាក់ព័ន្ធទៅនឹងផ្នែកមួយនៃអចលនទ្រព្យ និងទ្រព្យសម្ភារៈ ដែលបានទទួលស្គាល់រួចមក ហើយត្រូវបានបូកបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យសកម្ម នៅពេលដែលទ្រព្យសកម្មនេះ មានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដល់ធនាគារលើសពីស្តង់ដារដើម ។ រាល់ចំណាយបន្ទាប់ផ្សេងទៀតត្រូវបានទទួលស្គាល់ជាបន្ទុកចំណាយនៅក្នុងការិយបរិច្ឆេទដែលបានកើតឡើង ។

(iv) ចំណេញ ឬខាតពីការបោះចោល ឬការលក់ចេញនៃអចលនទ្រព្យ និងទ្រព្យសម្ភារៈណាមួយត្រូវបានកំណត់ ដោយភាពខុសគ្នារវាងប្រាក់ចំណូលសុទ្ធពីការលក់ និងតម្លៃយោងនៃអចលនទ្រព្យ និងទ្រព្យសម្ភារៈនោះ ហើយត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលនៅថ្ងៃបោះចោល ឬលក់ចេញ ។

(v) អចលនទ្រព្យ និងទ្រព្យសម្ភារៈ ដែលបានដករំលស់អស់ហើយ ត្រូវបានរក្សាទុកក្នុងរបាយការណ៍ហិរញ្ញវត្ថុ រហូតដល់ថ្ងៃដែលអចលនទ្រព្យ និងទ្រព្យសម្ភារៈទាំងនោះត្រូវបានលក់ ឬលុបបំបាត់ចោល ។

(vi) តម្លៃយោងនៃអចលនទ្រព្យ និងទ្រព្យសម្ភារៈ ត្រូវបានធ្វើការត្រួតពិនិត្យឡើងវិញ ចំពោះឱនភាពនៃតម្លៃ នៅពេលដែលមានការគូសបញ្ជាក់ណាមួយឱ្យដឹងថា អចលនទ្រព្យ និងទ្រព្យសម្ភារៈនោះចាំបាច់ត្រូវបន្ថយតម្លៃ ។ ឱនភាពនៃតម្លៃត្រូវបានវាស់វែង ដោយប្រៀបធៀបតម្លៃយោងរបស់អចលនទ្រព្យ និងទ្រព្យសម្ភារៈជាមួយតម្លៃដែលអាចប្រមូលបានវិញ ។ ការខាតបង់លើការថយចុះនៃតម្លៃ ត្រូវបានចាត់ចូលជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផល ។

ការដាក់បញ្ចូលមកវិញនូវការខាតបង់លើឱនភាព នៃតម្លៃដែលបានទទួលស្គាល់ពីឆ្នាំមុនៗ ត្រូវបានកត់ត្រាឡើងវិញ នៅពេលដែលមានការគូសបញ្ជាក់ឱ្យដឹងថា ការខាតបង់លើឱនភាពនៃតម្លៃដែលបានទទួលស្គាល់សំរាប់អចលនទ្រព្យ និងទ្រព្យសម្ភារៈ នោះលែងកើតមានទៀត ឬត្រូវបានថយចុះហើយ ។ ការដាក់បញ្ចូលមកវិញនេះ ត្រូវបានទទួលស្គាល់ត្រឹមកំរិតតម្លៃយោងនៃអចលនទ្រព្យ និងទ្រព្យសម្ភារៈ ដែលត្រូវបានកំណត់ (តម្លៃសុទ្ធបន្ទាប់ពីដករំលស់) ប្រសិនបើពុំមានការខាតបង់លើឱនភាពនៃតម្លៃទេនោះ ។ ការដាក់បញ្ចូល មកវិញនេះ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលផងដែរ ។

## (ដ) ឱនភាពនៃទ្រព្យសកម្ម

(i) *ទ្រព្យសកម្មហិរញ្ញវត្ថុ*

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាយតម្លៃនាកាលបរិច្ឆេទនៃការធ្វើរបាយការណ៍ ដើម្បីកំណត់ថាតើមានភស្តុតាងណាមួយដែលបង្ហាញថា ឱនភាពអាចកើតមានឡើង ។ ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវចាត់ទុកថាមានឱនភាពក្នុងករណីដែលអាចបង្ហាញថា មានហេតុការណ៍មួយឬច្រើនជះឥទ្ធិពលអវិជ្ជមានទៅលើចលនាសាច់ប្រាក់នាពេលអនាគតនៃទ្រព្យសកម្មនោះ ។ ករណីនេះ មិនត្រូវបានប្រើប្រាស់សម្រាប់ឥណទាននិងបុរេប្រទានដែលត្រូវបានបង្ហាញនៅក្នុងគោលការណ៍គណនេយ្យដោយឡែកនៅក្នុងកំណត់សំគាល់ 3 (ង) ។

ការខាតបង់លើឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានគណនាដោយផ្អែកលើភាពខុសគ្នារវាងតម្លៃនាពេលអនាគតដោយធ្វើការបញ្ចុះតម្លៃតាមអត្រាការប្រាក់ប្រសិទ្ធភាព ។

រាល់ទ្រព្យសកម្មសំខាន់ៗ ត្រូវបានត្រួតពិនិត្យទៅលើឱនភាពនៃតម្លៃតាមទ្រព្យសកម្មនីមួយៗ ។ ទ្រព្យសកម្មដែលនៅសល់ ត្រូវបានវាយតម្លៃជារួមសម្រាប់ទ្រព្យសកម្ម ដែលមានហានិភ័យឥណទានស្រដៀងគ្នា ។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល ។ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវដកចេញប្រសិនបើការដកចេញអាចពាក់ព័ន្ធជាមួយនឹងព្រឹត្តិ ការណ៍ដែលកើតឡើងក្រោយពីការទទួលស្គាល់ការខាតបង់ពីឱនភាព ។

(ii) *ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ*

តម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ត្រូវបានត្រួតពិនិត្យនៅរាល់កាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីកំណត់ថាតើមានកត្តា ដែលនាំឲ្យមានឱនភាពឬទេ ។ ក្នុងករណីដែលមានកត្តាទាំងនោះកើតឡើង ការប៉ាន់ស្មានតម្លៃដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្ម ត្រូវបានធ្វើឡើង ។

តម្លៃដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺផ្អែកលើតម្លៃ ដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃទីផ្សារ ដកចំណាយលក់ចេញ ។ ក្នុងការវាយតម្លៃលើតម្លៃប្រើប្រាស់សាច់ប្រាក់រំពឹងថានឹងទទួលបាននាពេលអនាគត ត្រូវបានបញ្ចុះ នៅតម្លៃបច្ចុប្បន្នដោយប្រើប្រាស់អត្រាការប្រាក់មុនដកពន្ធ ដែលឆ្លុះបញ្ចាំងតម្លៃទីផ្សារ ផ្អែកលើតម្លៃនៃពេលវេលា និងហានិភ័យជាក់លាក់សម្រាប់ទ្រព្យសកម្មទាំងនោះ ។

សម្រាប់គោលបំណងនៃការត្រួតពិនិត្យលើឱនភាពនៃតម្លៃទ្រព្យសកម្ម ត្រូវបានដាក់បញ្ចូលគ្នាទៅជាក្រុមតូចៗនៃទ្រព្យសកម្មដទៃទៀត ឬក្រុមទ្រព្យសកម្មដទៃទៀត("ឯកតាបង្កើតសាច់ប្រាក់") ។

## (ដ) ឱនភាពនៃទ្រព្យសកម្ម (ត)

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់មានចំនួនលើសពីតម្លៃ ដែលអាចប្រមូលមកវិញបាន ។ ការខាតបង់ពីឱនភាពនៃតម្លៃ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល ។

## (ឋ) ប្រាក់បញ្ញើរបស់អតិថិជន និងធនាគារនានា

ប្រាក់បញ្ញើរបស់អតិថិជន និងធនាគារនានា ត្រូវបានកត់ត្រាតាមតម្លៃនៃប្រាក់តម្កល់ ។

## (ឌ) ទ្រព្យអកម្មផ្សេងៗ

ទ្រព្យអកម្មផ្សេងៗ ត្រូវបានកត់ត្រាតាមតម្លៃដើម ។

## (ឍ) សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅក្នុងតារាងតុល្យការនៅពេលដែលធនាគារជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ឬកិច្ចសន្យា ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីពេលមុន និងអាចមានលទ្ធភាពដែលតម្រូវឱ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងការបំពេញនូវកាតព្វកិច្ចនោះ ។ ប្រសិនបើផលប៉ះពាល់មានលក្ខណៈជាសារវន្ត សំវិធានធន ត្រូវបានគេកំណត់ដោយការបញ្ចុះតម្លៃចលនាសាច់ប្រាក់ ដែលរំពឹងទុកនាពេលអនាគតតាមអត្រាមុនបង់ពន្ធ ដើម្បីឆ្លុះបញ្ចាំងពីការប៉ាន់ស្មានទីផ្សារបច្ចុប្បន្នតាមតម្លៃពេលវេលានៃរូបិយវត្ថុ និងដោយសមស្របទៅនឹងហានិភ័យជាក់លាក់នៃទ្រព្យអកម្ម ។

## (ណ) ការទទួលស្គាល់ប្រាក់ចំណូល

ចំណូលពីការប្រាក់លើឥណទាន និងប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា ត្រូវបានទទួលស្គាល់ ដោយផ្អែកលើមូលដ្ឋានបង្គរជារៀងរាល់ថ្ងៃ ។ ការប្រាក់លើឥណទានមិនដំណើរការមិនត្រូវបានកត់ត្រាជាចំណូលនោះទេ លុះត្រាតែវាទទួលបានជាសាច់ប្រាក់សុទ្ធ ។

ចំណូលពីសកម្មភាពផ្សេងៗរបស់ធនាគារ ត្រូវបានទទួលស្គាល់ដោយប្រើប្រាស់មូលដ្ឋាន ដូចខាងក្រោម:

(i) កំរៃលើការចាត់ចែងផ្តល់ឥណទាន និងកំរៃជើងសារលើសេវាកម្ម និងឥណទានដែលបានផ្តល់ទៅឱ្យអតិថិជន ត្រូវបានទទួលស្គាល់នៅពេលប្រតិបត្តិការកើតឡើង

(ii) កំរៃលើកិច្ចសន្យា និងកំរៃការធានាលើសេវាកម្មផ្សេងៗ និងឧបករណ៍ហិរញ្ញវត្ថុនានា ដែលផ្តល់ឱ្យអតិថិជនត្រូវបានទទួលស្គាល់ជាចំណូលនៅពេលតិបត្តិការកើតមានឡើង

(iii) កំរៃសេវាកម្ម និងកំរៃរត់ការ ត្រូវបានទទួលស្គាល់នៅពេលដែលសេវាកម្មត្រូវបានបំពេញ ។

## 3. គោលការណ៍គណនេយ្យសំខាន់ៗ (ត)

### (ត) ចំណាយលើការប្រាក់

ចំណាយលើការប្រាក់ទៅលើប្រាក់បញ្ញើរបស់អតិថិជន ត្រូវបានទទួលស្គាល់តាមមូលដ្ឋានបង្គរជារៀងរាល់ថ្ងៃ ។

### (ថ) ចំណាយលើប្រតិបត្តិការជួល

ថ្លៃឈ្នួលដែលបានបង់លើកិច្ចសន្យាជួល សំរាប់ប្រតិបត្តិការ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ លទ្ធផលតាមវិធីសាស្ត្ររំលស់ថេរទៅតាមពេលកំណត់នៃការជួល ។

### (ទ) ពន្ធលើប្រាក់ចំណេញ

(i) ពន្ធលើប្រាក់ចំណេញទៅលើការចំណេញ ឬខាតប្រចាំឆ្នាំរួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ ។ ពន្ធលើប្រាក់ចំណេញក្នុងការិយបរិច្ឆេទ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលលើកលែងតែ ក្នុងករណីដែលពន្ធនោះទាក់ទងទៅនឹងសមាសធាតុ ដែលត្រូវទទួលស្គាល់ជាផ្នែកមួយនៃមូលនិធិម្ចាស់ហ៊ុន ។ ក្នុងករណីនេះក៏ត្រូវបានកំណត់បង្ហាញជាផ្នែកមួយនៃមូលនិធិម្ចាស់ហ៊ុនផងដែរ ។

ពន្ធលើប្រាក់ចំណេញក្នុងការិយបរិច្ឆេទ គឺជាពន្ធដែលនឹងត្រូវបង់ទៅលើប្រាក់ចំណេញជាប់ពន្ធក្នុងការិយបរិច្ឆេទ ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានកំណត់ជាអាទ៍នៅថ្ងៃតារាងតុល្យការជាមួយនឹងនិយ័តកម្មណាមួយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗ ។

(ii) ពន្ធពន្យារ ត្រូវបានកត់ត្រាតាមវិធីសាស្ត្រតារាងតុល្យការទៅលើភាពលំអៀងជាបណ្តោះអាសន្ន រវាងតម្លៃយោងនៃទ្រព្យសកម្ម និងទ្រព្យអកម្ម ក្នុងគោលបំណងនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃដែលប្រើក្នុងគោលបំណងនៃការគិតពន្ធ ។ តម្លៃនៃប្រាក់ពន្ធពន្យារដែលបានកំណត់នោះ គឺផ្អែកលើលក្ខណៈនៃការជឿជាក់នឹងទទួលបាន ឬការទូទាត់ដែលនឹងកើតឡើងរវាងតម្លៃសុទ្ធនៃទ្រព្យសកម្ម និងទ្រព្យអកម្ម ដោយប្រើអត្រាពន្ធកំណត់នៅថ្ងៃតុល្យការ ។

ពន្ធពន្យារលើទ្រព្យសកម្ម ត្រូវបានទទួលស្គាល់តែក្នុងករណីអាចនឹងកើតមានឡើងទៅលើប្រាក់ចំណេញជាប់ពន្ធ នាពេលអនាគតដែលអាចប្រើប្រាស់ជាមួយនឹងទ្រព្យសកម្ម ។ ពន្ធពន្យារលើទ្រព្យសកម្មនេះ ត្រូវបានកាត់បន្ថយក្នុងករណីដែលមិនអាចកើតឡើងនូវអត្ថប្រយោជន៍នៃពន្ធដែលពាក់ព័ន្ធដែលអាចនឹងប្រើប្រាស់បាន ។

## 3. គោលការណ៍គណនេយ្យសំខាន់ៗ (ត)

### (ធ) សម្ព័ន្ធញាតិ

ភាគីដែលត្រូវបានចាត់ទុកជាសម្ព័ន្ធញាតិរបស់ធនាគារ ប្រសិនបើភាគីនោះមានលទ្ធភាពគ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោលលើភាគីមួយទៀត ឬមានឥទ្ធិពលយ៉ាងខ្លាំងទៅលើភាគីនេះក្នុងការធ្វើសេចក្តីសំរេចលើផ្នែកហិរញ្ញវត្ថុ និងប្រតិបត្តិការ ។ ដូចគ្នានេះដែរ ប្រសិនបើធនាគារនិងភាគីនោះស្ថិតនៅក្រោមការគ្រប់គ្រងរួមមួយ ឬក៏មានឥទ្ធិពលយ៉ាងខ្លាំង ។ សម្ព័ន្ធញាតិអាចជារូបវន្តបុគ្គល ឬនិតិបុគ្គល និងរួមបញ្ចូលនូវរូបវន្តបុគ្គលណាម្នាក់នៃសមាជិកគ្រួសារដែលជិតស្និទ្ធ ក៏ត្រូវបានចាត់ទុកជាសម្ព័ន្ធញាតិដែរ ។

នៅក្រោមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និយមន័យរបស់សម្ព័ន្ធញាតិរួមបញ្ចូលផងដែរនូវភាគីដែលកាន់កាប់ភាគហ៊ុនដោយផ្ទាល់ឬដោយប្រយោលយ៉ាងតិច 10% នៃដើមទុន ឬនៃសិទ្ធិបោះឆ្នោត ហើយរាប់បញ្ចូលនូវរូបវន្តបុគ្គលណាម្នាក់ដែល រួមចំណែកក្នុងការអភិបាល ការដឹកនាំការគ្រប់គ្រង ឬការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ ។

### (ន) ស្តង់ដារ និងការបកស្រាយថ្មី ដែលមិនទាន់បានអនុវត្ត

ដូចមានចែងក្នុងប្រកាសលេខ 068 សហវ-ប្រក ចុះថ្ងៃទី 8 ខែ មករា ឆ្នាំ 2009 ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តន៍ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជា ក្រុមប្រឹក្សាជាតិគណនេយ្យ បានអនុម័តឱ្យប្រើស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ ដែលមានប្រសិទ្ធភាពអនុវត្តន៍ចំពោះរបាយការណ៍ហិរញ្ញវត្ថុសំរាប់ការិយបរិច្ឆេទចាប់ផ្តើមនៅ ឬបន្ទាប់ពីថ្ងៃទី 1 ខែ មករា ឆ្នាំ 2012 ។ ស្តង់ដារថ្មីនេះនឹងត្រូវបានកំណត់ជាស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។ គណៈគ្រប់គ្រងកំពុងធ្វើការវាយតំលៃលើផលប៉ះពាល់សំខាន់ៗនៃស្តង់ដារនេះ ។

## 4. ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅជាប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាដុល្លារអាមេរិក ។ ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅជាប្រាក់រៀល ត្រូវបានធ្វើឡើងដើម្បីអនុវត្តទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដោយប្រើប្រាស់អត្រាប្តូរប្រាក់មធ្យមជាផ្លូវការ ប្រកាសដោយធនាគារជាតិនៃកម្ពុជា នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010 ដែល 1 ដុល្លារអាមេរិក ស្មើនឹង 4.053 រៀល ។ តួលេខជាប្រាក់រៀលនេះ គឺសំរាប់ជាការបង្ហាញតែប៉ុណ្ណោះ ហើយមិនត្រូវបានយកមកបកស្រាយ ថាតួលេខប្រាក់ដុល្លារអាមេរិកនេះត្រូវបានប្តូរទៅជាប្រាក់រៀល ឬនឹងត្រូវបានប្តូរជាប្រាក់រៀល នាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ ។

## 5. សាច់ប្រាក់ និងសមតុល្យធនាគារ

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល (កំណត់សំគាល់ទី 4) | 2009 ដុល្លារអាមេរិក |
|---|---|---|---|
| សាច់ប្រាក់ក្នុងដៃ | 2,235,836 | 9,061,843 | 740,617 |
| សមតុល្យធនាគារក្នុងព្រះរាជាណាចក្រកម្ពុជា: | | | |
| ធនាគារជាតិនៃកម្ពុជា | 2,527,237 | 10,242,892 | 803,838 |
| ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ | 14,959 | 60,628 | - |
| ធនាគារផ្សេងៗ | 676 | 2,740 | 9,624 |
| សមតុល្យធនាគារក្រៅព្រះរាជាណាចក្រកម្ពុជា: | | | |
| Korea Exchange Bank | 2,529,507 | 10,252,092 | 160,004 |
| Kookmin Bank (Korea) | 39,851 | 161,516 | - |
| ING Belgium NV/VA | 478,092 | 1,937,707 | - |
| Wachovia Bank | - | - | 1,448,669 |
| | 7,826,158 | 31,719,418 | 3,162,752 |

តាមរូបិយប័ណ្ណ:

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល (កំណត់សំគាល់ទី 4) | 2009 ដុល្លារអាមេរិក |
|---|---|---|---|
| ប្រាក់ដុល្លារអាមេរិក | 7,808,093 | 31,646,201 | 3,160,973 |
| ប្រាក់រៀល | 18,065 | 73,217 | 1,779 |
| | 7,826,158 | 31,719,418 | 3,162,752 |

សមតុល្យធនាគារ គឺជាគណនីចរន្តដែលតម្កល់នៅធនាគារនានា ។

## 6. ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា

| | 2010 | | 2009 |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល<br>(កំណត់សំគាល់ទី 4) | ដុល្លារអាមេរិក |
| នៅក្នុងព្រះរាជាណាចក្រកម្ពុជា: | | | |
| ធនាគារកាណាឌីយ៉ា ភីអិលស៊ី | 11,112,909 | 45,040,621 | 4,048,456 |
| ធនាគារខេមខូ លីមីធីត | 2,094,247 | 8,487,983 | 2,023,633 |
| ធនាគារគូកមីន កម្ពុជា ភីអិលស៊ី | 7 | 28 | 2,029,409 |
| ធនាគារអង្គរ កាពីតាល ភីអិលស៊ី | 1,500,000 | 6,079,500 | 4,047,938 |
| ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ | 3,065,340 | 12,423,823 | 2,500,000 |
| ធនាគារសហពាណិជ្ជ ក.អ | 4,000,000 | 16,212,000 | - |
| | 21,772,503 | 88,243,955 | 14,649,436 |

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារត្រូវបានធ្វើការវិភាគ ដូចខាងក្រោម:

(ក) តាមកាលកំណត់:

| | 2010 | | 2009 |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល<br>(កំណត់សំគាល់ទី 4) | ដុល្លារអាមេរិក |
| រយៈពេល 1 ខែ | 1,772,503 | 7,183,955 | 4,601,498 |
| 2 ទៅ 3 ខែ | 8,000,000 | 32,424,000 | 7,547,938 |
| 4 ទៅ 6 ខែ | 12,000,000 | 48,636,000 | 2,500,000 |
| | 21,772,503 | 88,243,955 | 14,649,436 |

(ខ) តាមរូបិយប័ណ្ណ:

| | | | |
|---|---|---|---|
| ប្រាក់ដុល្លារអាមេរិក | 21,772,503 | 88,243,955 | 14,649,436 |

(គ) តាមអត្រាការប្រាក់ (ប្រចាំឆ្នាំ):

| | 2010 | 2009 |
|---|---|---|
| ធនាគារកាណាឌីយ៉ា ភីអិលស៊ី | 0.50% - 6.00% | 1.50% - 4.50% |
| ធនាគារ ខេមខូ លីមីធីត | 1.50% - 3.90% | 1.00% - 3.90% |
| ធនាគារ គូកមីន កម្ពុជា ភីអិលស៊ី | 0.50% | 1.00% - 4.70% |
| ធនាគារ អង្គរ កាពីតាល ភីអិលស៊ី | 4.25% - 5.25% | 5.25% - 7.70% |
| ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ | 1.00% - 4.00% | 4.00% - 6.25% |
| ធនាគារសហពាណិជ្ជ ក.អ | 4.00% | - |

## 7. ឥណទាន និងបុរេប្រទានសុទ្ធ

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល (កំណត់សំគាល់ទី 4) | 2009 ដុល្លារអាមេរិក |
|---|---|---|---|
| ឥណទានវិបារូបន៍ | 1,885,996 | 7,643,942 | 1,591,809 |
| ឥណទានពាណិជ្ជកម្ម | | | |
| ឥណទានរយៈពេលវែង | 7,881,068 | 31,941,969 | 4,989,906 |
| ឥណទានរយៈពេលខ្លី | 14,979,900 | 60,713,534 | 6,183,733 |
| ឥណទានអ្នកប្រើប្រាស់ | | | |
| ឥណទានផ្ទែកគេហដ្ឋាន | - | - | 31,944 |
| | 24,746,964 | 100,299,445 | 12,797,392 |
| សំវិធានធនលើឥណទាននិងបុរេប្រទាន អាក្រក់ និងជាប់សង្ស័យ | (247,469) | (1,002,992) | (136,974) |
| | 24,499,495 | 99,296,453 | 12,660,418 |

បំរែបំរួលនៃសំវិធានធនសំរាប់ឥណទាន និងបុរេប្រទានអាក្រក់និងជាប់សង្ស័យ មានដូចខាងក្រោមៈ

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល (កំណត់សំគាល់ទី 4) | 2009 ដុល្លារអាមេរិក |
|---|---|---|---|
| នាដើមការិយបរិច្ឆេទ | 136,974 | 555,156 | 53,418 |
| សំវិធានធនបានធ្វើបន្ថែមក្នុងការិយបរិច្ឆេទ | | | |
| -សំវិធានធនទូទៅ | 110,495 | 447,836 | 74,556 |
| - សំវិធានធនជាក់លាក់ | - | - | 9,000 |
| នាចុងការិយបរិច្ឆេទ | 247,469 | 1,002,992 | 136,974 |

## 7. ឥណទាន និងបុរេប្រទានសុទ្ធ (ត)

| | 2010 | | 2009 |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ទី 4) | ដុល្លារអាមេរិក |
| (ក) តាមកាលកំណត់: | | | |
| រយៈពេល 1 ខែ | 577,590 | 2,340,972 | - |
| 2 ទៅ 3 ខែ | 1,887,584 | 7,650,378 | - |
| 4 ទៅ 6 ខែ | 3,905,706 | 15,829,827 | 4,249,542 |
| 7 ទៅ 12 ខែ | 10,270,588 | 41,626,693 | 3,526,000 |
| 1 ទៅ 3 ឆ្នាំ | 8,105,496 | 32,851,575 | 5,021,850 |
| | 24,746,964 | 100,299,445 | 12,797,392 |
| (ខ) តាមប្រភេទអាជីវកម្ម: | | | |
| គ្រឹះស្ថានហិរញ្ញវត្ថុ | 1,046,017 | 4,239,507 | 878,200 |
| ផលិតកម្ម | 1,266,000 | 5,131,098 | 450,000 |
| សេវាកម្ម | 7,760,518 | 31,453,379 | 2,728,237 |
| ការនាំចូល | 718,334 | 2,911,408 | 650,000 |
| ការនាំចេញ | 325,000 | 1,317,225 | - |
| លក់ដុំ និងលក់រាយ | 5,692,394 | 23,071,273 | 2,132,030 |
| កសិកម្ម | 114,300 | 463,258 | 85,000 |
| ផ្នែកគេហដ្ឋាន | - | - | 31,944 |
| អចលនទ្រព្យ និងការសាងសង់ | 6,507,884 | 26,376,454 | 5,841,981 |
| អាជីវកម្មផ្សេងៗ | 1,316,517 | 5,335,843 | - |
| | 24,746,964 | 100,299,445 | 12,797,392 |

## 7. ឥណទាន និងបុរេប្រទានសុទ្ធ (ត)

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល (កំណត់សំគាល់ទី 4) | 2009 ដុល្លារអាមេរិក |
|---|---|---|---|
| **(គ) តាមប្រភេទអតិថិជនៈ** | | | |
| និតិបុគ្គល | 7,339,255 | 29,746,000 | 7,048,242 |
| រូបវន្តបុគ្គល | 17,407,709 | 70,553,445 | 5,749,150 |
| | 24,746,964 | 100,299,445 | 12,797,392 |
| **(ឃ) តាមរូបិយប័ណ្ណៈ** | | | |
| ប្រាក់ដុល្លារអាមេរិក | 24,746,964 | 100,299,445 | 12,797,392 |
| **(ង) តាមនិវាសនដ្ឋានៈ** | | | |
| និវាសនជន | 24,746,964 | 100,299,445 | 12,797,392 |
| **(ច) តាមទំនាក់ទំនងសម្ព័ន្ធញាតិៈ** | | | |
| ភាគីមិនមែនសម្ព័ន្ធញាតិ | 24,746,964 | 100,299,445 | 12,797,392 |
| **(ឆ) តាមចំណាត់ថ្នាក់ឥណទានៈ** | | | |
| បំណុលធម្មតា/ស្តង់ដារ | | | |
| មានវត្ថុបញ្ចាំ | 24,746,964 | 100,299,445 | 12,347,392 |
| គ្មានវត្ថុបញ្ចាំ | - | - | - |
| បំណុលឃ្លាំមើល | | | |
| មានវត្ថុបញ្ចាំ | - | - | 450,000 |
| គ្មានវត្ថុបញ្ចាំ | - | - | - |
| | 24,746,964 | 100,299,445 | 12,797,392 |
| **(ជ) តាមហានិភ័យៈ** | | | |
| ហានិភ័យធំៗ | 1,897,738 | 7,691,532 | 1,491,938 |
| មិនមែនជាហានិភ័យធំៗ | 22,849,226 | 92,607,913 | 11,305,454 |
| | 24,746,964 | 100,299,445 | 12,797,392 |

## 7. ឥណទាន និងបុរេប្រទានសុទ្ធ (ត)

(ជ) តាមហានិភ័យ: (ត)

ហានិភ័យធំ ត្រូវបានផ្តល់និយមន័យ នៅក្នុងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ថាជាសមតុល្យសរុបនៃឥណទាន និងបុរេប្រទានដែលផ្តល់ដល់អតិថិជនម្នាក់លើស ពី 10% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ។ ហានិភ័យនេះសំដៅលើចំនួនប្រាក់ខ្ពស់ បំផុតរវាងសមតុល្យនៃឥណទាន និងទាយជ្ជទានដែលនៅសល់ ឬឥណទាន និង ទាយជ្ជទានដែលបានអនុម័ត ។

(ឈ) តាមអត្រាការប្រាក់ (ប្រចាំឆ្នាំ):

| | 2010 | 2009 |
|---|---|---|
| ឥណទានវិបារូបន៍ | 12.00%-14.00% | 12.00%-18.00% |
| ឥណទានកម្ចី | 10.00%-20.00% | 12.00%-20.00% |

## 8. ទ្រព្យសកម្មផ្សេងៗ

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល (កំណត់សំគាល់ទី 4) | 2009 ដុល្លារអាមេរិក |
|---|---|---|---|
| ការប្រាក់ត្រូវទទួលពីឥណទាន និងបុរេប្រទាន | 155,875 | 631,761 | 64,256 |
| ការប្រាក់ត្រូវទទួលពីប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា | 156,786 | 635,454 | 82,946 |
| ចំណាយប្រាក់កក់លើថ្លៃជួល | 132,900 | 538,644 | 90,900 |
| ចំណាយបង់មុនលើការផ្សាយពាណិជ្ជកម្ម | 11,070 | 44,867 | 9,967 |
| ចំណាយបង់មុនលើសេវាកម្មជួសជុល | 18,879 | 76,517 | 17,121 |
| ទ្រព្យសកម្មផ្សេងៗ | 150,119 | 608,432 | 1,568 |
| | 625,629 | 2,535,675 | 266,758 |

## 9. ប្រាក់បញ្ញើតម្កល់តាមច្បាប់

| | 2010 ដុល្លារអាមេរិក | 2010 ពាន់រៀល (កំណត់សំគាល់ទី 4) | 2009 ដុល្លារអាមេរិក |
|---|---|---|---|
| ប្រាក់បញ្ញើតម្កល់តាមច្បាប់លើ: | | | |
| ដើមទុនចុះបញ្ជី | 1,500,000 | 6,079,500 | 1,500,000 |
| ប្រាក់បញ្ញើរបស់អតិថិជន | 1,337,000 | 5,418,861 | 727,000 |
| | 2,837,000 | 11,498,361 | 2,227,000 |

ប្រាក់បញ្ញើតម្កល់តាមច្បាប់ ត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជាស្របតាមមាត្រាទី 5 នៃប្រកាសរបស់ធនាគារជាតិនៃព្រះរាជាណាចក្រកម្ពុជាលេខ ធ7-01-136ប្រក ។ ប្រាក់បញ្ញើទាំងនេះត្រូវបានកំណត់ជាភាគរយនៃដើមទុនអប្បបរមារបស់ធនាគារតាមអត្រា 10% និងប្រាក់បញ្ញើរបស់អតិថិជននៅធនាគារតាមអត្រា 8% ។ ប្រាក់បញ្ញើតម្កល់តាមច្បាប់ខាងលើនេះ ត្រូវបានធ្វើការវិភាគបន្ថែម ដូចខាងក្រោម:

### (ក) ប្រាក់បញ្ញើតម្កល់តាមច្បាប់លើដើមទុនអប្បបរមា

ប្រាក់បញ្ញើនេះ គឺប្រាក់តម្កល់ធានាលើដើមទុនអប្បបរមាស្មើនឹង 10% នៃដើមទុន ចុះបញ្ជីរបស់ធនាគារស្របតាមមាត្រាទី 1 នៃប្រកាសលេខ ធ7-01-136ប្រក ស្តីពីប្រាក់តម្កល់ធានាលើដើមទុនរបស់ធនាគារ ចុះថ្ងៃទី 15 ខែ តុលា ឆ្នាំ 2001 ។ ប្រាក់បញ្ញើនេះ ត្រូវបានតម្កល់ទុកជាមួយធនាគារជាតិនៃកម្ពុជាជាប្រាក់ដុល្លារអាមេរិក ហើយអាចដកមកវិញបាននៅពេលធនាគារបញ្ចប់ប្រតិបត្តិការអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ក្នុងកំឡុងការិយបរិច្ឆេទ ធនាគារទទួលបានការប្រាក់ស្មើនឹង 1/4 នៃអត្រា SIBOR គិតលើមូលដ្ឋាន 6 ខែ ដែល មានអត្រាចាប់ពី 0.11% ទៅ 0.18% ក្នុងមួយឆ្នាំ (2009: 0.28% ទៅ 0.68% ក្នុងមួយឆ្នាំ) ។

### (ខ) ប្រាក់បញ្ញើតម្កល់តាមច្បាប់លើប្រាក់បញ្ញើរបស់អតិថិជន

ប្រាក់បញ្ញើនេះ គឺប្រាក់តម្កល់បំរុងកាតព្វកិច្ចលើប្រាក់បញ្ញើរបស់អតិថិជន ដែលប្រែប្រួល ដោយផ្អែកទៅលើកំរិតប្រែប្រួលនៃប្រាក់បញ្ញើរបស់អតិថិជននៅធនាគារ ។ ប្រាក់តម្កល់បំរុងកាតព្វកិច្ចនេះត្រូវរក្សាទុកស្របតាមប្រកាសលេខ ធ7-09-020 ប្រក របស់ធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី 26 ខែ មករា ឆ្នាំ 2009 តាមអត្រាការប្រាក់ 8% នៃប្រាក់បញ្ញើរបស់អតិថិជន ជាប្រាក់រៀល និង 12% នៃប្រាក់បញ្ញើរបស់អតិថិជនជារូបិយប័ណ្ណក្រៅពីប្រាក់រៀល ។ ប្រាក់បញ្ញើតម្កល់ជារូបិយប័ណ្ណក្រៅពីប្រាក់រៀលចំនួន 4% ទទួលបានអត្រាការប្រាក់ស្មើនឹង 1/2 នៃ អត្រា SIBOR គិតលើមូលដ្ឋានមួយខែ ហើយចំនួន 8% ដែលនៅសល់ និងប្រាក់បញ្ញើតម្កល់ជាប្រាក់រៀលមិនទទួលបានការប្រាក់នោះទេ ។

## 10. ទ្រព្យសកម្មអរូបិយ

| | សូហ្វវែរកុំព្យូទ័រ (Moneta) ដុល្លារអាមេរិក | SWIFT សូហ្វវែរ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក | សរុប ពាន់រៀល (កំណត់សំគាល់ទី 4) |
|---|---|---|---|---|
| **តម្លៃដើម** | | | | |
| នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2010 | 428,125 | 33,875 | 462,000 | 1,872,486 |
| ការទិញបន្ថែម | 7,765 | - | 7,765 | 31,471 |
| នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010 | 435,890 | 33,875 | 469,765 | 1,903,957 |
| ដក: **រំលស់បង្គរ** | | | | |
| នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2010 | 105,180 | 21,599 | 126,779 | 513,835 |
| រំលស់ក្នុងឆ្នាំ | 87,116 | 12,276 | 99,392 | 402,836 |
| នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010 | 192,296 | 33,875 | 226,171 | 916,671 |
| **តម្លៃសុទ្ធ** | | | | |
| នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010 | 243,594 | - | 243,594 | 987,286 |
| នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2009 | 322,945 | 12,276 | 335,221 | |

## 11. អចលនទ្រព្យ និងទ្រព្យសម្ភារៈ

| | ការជួសជុលកែលំអរ ដុល្លារអាមេរិក | គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ ដុល្លារអាមេរិក | កុំព្យូទ័រនិងសម្ភារៈការិយាល័យ ដុល្លារអាមេរិក | យានយន្ត ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក | សរុប ពាន់រៀល (កំណត់សំគាល់ទី 4) |
|---|---|---|---|---|---|---|
| **តម្លៃដើម** | | | | | | |
| នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2010 | 522,958 | 225,826 | 270,177 | 97,439 | 1,116,400 | 4,524,769 |
| ការទិញបន្ថែម | 22,106 | 37,216 | 50,521 | 3,040 | 112,883 | 457,515 |
| ការចាត់ថ្នាក់ឡើងវិញ | (26,678) | 26,678 | - | - | - | - |
| នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2010 | 518,386 | 289,720 | 320,698 | 100,479 | 1,229,283 | 4,982,284 |
| ដក: **រំលស់បង្គរ** | | | | | | |
| នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2010 | 110,846 | 66,140 | 164,226 | 31,614 | 372,826 | 1,511,064 |
